# ព្រះបទុមចេតិយ

## វត្តមណីរតនារាម



រៀបរៀងដោយៈ

ឧបាសក សាន សុជា

ព.ស. ២៥៦៧ គ.ស. ២០២៤

# ព្រះបទុមចេតិយ

## វត្តមណីរតនារាម



រៀបរៀងដោយៈ

**ឧបាសក សាន សុជា**

ព.ស. ២៥៦៧ គ.ស. ២០២៤

# ពាក្យប្រារព្ធ

**ព្រះបទុមចេតិយ** គឺជាព្រះ**ចេតិយ** តម្កល់**ព្រះបរមសារីរិកធាតុ**នៃ**ព្រះសម្មាសម្ពុទ្ធបរមគ្រូ** ទុកជាទីគោរពសក្ការៈ នៃពុទ្ធបរិស័ទមកពីគ្រប់មជ្ឈដ្ឋាន ដែលបានចាប់ផ្ដើមកសាងឡើង តាំងពីឆ្នាំ២០០៩ រហូតមកដល់សព្វថ្ងៃ ហើយនឹងត្រូវសម្ពោធឆ្លងនៅដំណាច់ខែមីនា ឆ្នាំ២០២៤ ខាងមុខនេះ។ ដើម្បីជា**ធម្មទាន**ក្នុងឱកាសបុណ្យ**សម្ពោធឆ្លង**ដ៏ខ្ពង់ខាងមុខ ខ្ញុំក៏ចាប់ផ្ដើមសរសេរសៀវភៅនេះឡើង រៀបរាប់អំពីប្រវត្តិខ្លះៗ នៃការកសាង**ព្រះចេតិយ**នេះ អមទៅដោយ**ព្រះធម៌**គួរសិក្សាមួយចំនួន ដើម្បីជាគ្រឿងដាស់តឿនស្មារតីនៃពុទ្ធបរិស័ទ ដែលមានសទ្ធាជ្រះថ្លាក្នុង**ព្រះពុទ្ធសាសនា**ស្រេចស្រាប់ហើយ និងសម្រាប់សាធុជនមួយចំនួនទៀត ដែលបម្រុងនឹងសាកល្បងឈ្វេងយល់អំពី**ព្រះពុទ្ធសាសនា**។

ម្យ៉ាងទៀត ដោយ**ព្រះបទុមចេតិយ**នេះ ខ្ញុំបានដឹកនាំកសាងតាំងពីខ្ញុំនៅក្នុងភាពជាភិក្ខុវជិរប្បញ្ញោ **សាន សុជា** ដូច្នេះ ក្នុងការសរសេរតទៅនេះ ការប្រើពាក្យថា “ខ្ញុំៗ” គឺជាពាក្យដែលប្រើក្នុងនាមជាភិក្ខុវជិរប្បញ្ញោ **សាន សុជា** នោះឯង។

សៀវភៅនេះ ថ្វីដ្បិតតែមានចំនួនទំព័រមិនច្រើនប៉ុន្មាន ប៉ុន្តែខ្ញុំសង្ឃឹមថា នឹងបានជាអារម្មណ៍ដែលនាំឱ្យកើតសេចក្ដីជ្រះថ្លាបន្ថែមទៀត ដល់ពុទ្ធបរិស័ទដែលកំពុងកាន់អានដោយយកចិត្តទុកដាក់។

សូមអ្នកអានទាំងឡាយ ទទួលនូវការគោរពស្រឡាញ់អំពីខ្ញុំព្រះករុណា ខ្ញុំ។

ប្រទេសអូស្ត្រាលី ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៤

ឧបាសក **សាន សុជា**

# មាតិកា

| | |
|---|---|
| | ទំព័រ |
| វត្តមណីរតនារាម ........................................ | ១ |
| ហេតុនាំឱ្យកើតគំនិតកសាងព្រះបទុមចេតិយ ................ | ៣ |
| បុព្វហេតុនៃការគូរប្លង់ព្រះបទុមចេតិយ ..................... | ៥ |
| អ្នកជំរុញឱ្យចាប់ផ្ដើមការសាងសង់ព្រះបទុមចេតិយ ......... | ៧ |
| ការរៀបគម្រោងសាងសង់ព្រះបទុមចេតិយ ................... | ៩ |
| ការចាប់ផ្ដើមសាងសង់ព្រះបទុមចេតិយ ...................... | ១២ |
| ការបង្កើតកម្លាំងពិត ............................................ | ១៤ |
| រូបភាពបង្ហាញពីដំណើរការនៃការកសាង .................... | ១៧ |
| ការបញ្ចប់កិច្ចការដែលសេសសល់ ............................ | ២៨ |
| អត្ថន័យសំខាន់ៗអំពីព្រះបទុមចេតិយ ....................... | ២៩ |
| ទីធ្លាជុំវិញព្រះបទុមចេតិយ ..................................... | ៣០ |
| បដិមាព្រះអសីតិមហាសាវក ៨០ អង្គ ......................... | ៣២ |
| ផ្កាឈូកទ្រព្រះចេតិយ ............................................ | ៣៤ |
| ឧបាសក ឧបាសិកាមិនល្អព្រោះគុណវិបត្តិ ៥ យ៉ាង .......... | ៣៤ |
| ឧបាសក ឧបាសិកាល្អដោយគុណសម្បត្តិ ៥ យ៉ាង .......... | ៣៥ |
| ព្រះសាវក ៦០ អង្គ ............................................... | ៣៧ |
| ព្រះពុទ្ធ ២៨ ព្រះអង្គ ............................................ | ៣៩ |
| អាដានាដិយបរិត្ត ................................................. | ៣៩ |
| ព្រះពុទ្ធបដិមាថ្មម៉ាបច្រើនព្រះអង្គ .............................. | ៤៤ |
| រតនៈដ៏កម្រ ៥ យ៉ាង ............................................. | ៤៥ |

រូបធ្លាក់ផុសចេញពីជញ្ជាំងទាំង ៤ ទិស .................... ៤៨
កន្ទែងតម្កល់ព្រះសារីរិកធាតុ ..................................... ៥១
ប្រវត្តិសង្ខេបនៃព្រះសារីរិកធាតុ ................................ ៥១
ការបែងចែកព្រះសារីរិកធាតុ .................................... ៥៣
ធាតុចេតិយនមស្ការគាថា ........................................ ៥៥
ស្រទាប់ផ្កាឈូក ៥ ថ្នាក់ ............................................ ៦០
សុទ្ធាវាសភូមិ ៥ ....................................................... ៦០
កំពូលព្រះបទុមចេតិយ ........................................... ៦២
លម្អរបស់ព្រះនិព្វាន ................................................ ៦៣
មហាសុបិន ៥ ប្រការ ............................................... ៦៥
មហាសុបិនទី ១ ...................................................... ៦៥
មហាសុបិនទី ២ ...................................................... ៦៧
មហាសុបិនទី ៣ ...................................................... ៦៨
មហាសុបិនទី ៤ ...................................................... ៦៩
មហាសុបិនទី ៥ ...................................................... ៧០
អ្នកមានឧបការៈក្នុងការជួយរៀបចំសៀវភៅនេះ ............ ៧១
សៀវភៅធម៌ដែលបានរៀបរៀង
ដោយ ភិក្ខុវជិរប្បញ្ញោ សាន សុជា ............................ ៧២
សៀវភៅធម៌ដែលបានរៀបរៀង
ដោយ ឧបាសក សាន សុជា ...................................... ៧៣

# ~ ១ ~

# វត្តមណីរតនារាម

មុននឹងរៀបរាប់អំពី**ព្រះបទុមចេតិយ** ខ្ញុំសូមបរិយាយខ្លះៗ អំពី**វត្តមណីរតនារាម**ជាមុន ព្រោះ**ព្រះចេតិយ**នេះ បានកសាងក្នុងទីដីនៃ**វត្តមណីរតនារាម**។ ទីដីនេះ កាលដើមឡើយជាស្រែជម្រៅ និងជាកម្មសិទ្ធិរបស់លោក **ជុកម៉ិល សន្តិភាព** និងឧបាសិកា **ជា កែវមុនី**។ ក្នុងឆ្នាំ២០០១ ម្ចាស់ដីមានសទ្ធាជ្រះថ្លា បានប្រគេនដីនេះដល់ខ្ញុំ ដើម្បីរៀបចំធ្វើជា**មណ្ឌលសិក្សា** ដោយក្នុងកាលនោះបានឯកភាពគ្នាជាមួយអាចារ្យ គណៈកម្មការ និងសមាជិកទាំងអស់ ដាក់ឈ្មោះថា **ពុទ្ធសាសនមណ្ឌលមណីរត្ន** ដែលក្នុងកាលនោះ ខ្ញុំមានតួនាទីជា **អធិបតីនៃមណ្ឌល**។ ក្រោយការស្នើសុំសិទ្ធបង្កើត**មណ្ឌល** មិនយូរប៉ុន្មាន **មន្ទីរធម្មការនិងសាសនា**ខេត្តពោធិ៍សាត់ បានឯកភាពតាមលិខិតលេខ ម.ធ.ស.ព.ស ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០១។ **ពុទ្ធសាសនមណ្ឌលមណីរត្ន** ក៏ត្រូវបានចាប់ផ្តើមកសាងតាំងពីពេលនោះមក។



ឧបាសក **ជុកម៉ិល សន្តិភាព** និងឧបាសិកា **ជា កែវមុនី** អ្នកមានសទ្ធាប្រគេនដីឱ្យផ្តើមកសាង

ក្រោយមក ដោយមានព្រះយោបល់ស្នើសុំអំពី**គណៈសង្ឃ** ថាសុំឱ្យដូរឈ្មោះ**មណ្ឌល** កុំឱ្យជាន់គ្នានឹង**ពុទ្ធមណ្ឌលកម្ពុជា** ទីនេះក៏បានប្តូរឈ្មោះជា **មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន** ដូច្នេះវិញ។

ពីមួយឆ្នាំទៅមួយឆ្នាំ ដោយឃើញការសិក្សា**ព្រះធម៌ ព្រះវិន័យ** របស់ព្រះសង្ឃ និងពុទ្ធបរិស័ទកាន់តែរីកចម្រើន ចំនួនភិក្ខុសាមណេរដែលមកសុំស្នាក់នៅរៀនសូត្រក៏កាន់តែច្រើន ការសាងសង់សេនាសនៈ និងការទិញដីពង្រីកក៏កាន់តែច្រើន ហើយបានជំទូលាយជាងពីពេលចាប់ផ្តើមដំបូងទាំងការផ្សព្វផ្សាយ**ព្រះធម៌**តាមវិទ្យុ និងទូរទស្សន៍ក៏កាន់តែមានវិសាលភាព ទើបនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ ឯកឧត្តម **មិន ឃិន** ដែលក្នុងកាលនោះ ជា**រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា** បានសម្រេចកែប្រែ**មណ្ឌលសិក្សា**នេះ ឱ្យក្លាយជាវត្ត ពេញលក្ខណៈ និងមានឈ្មោះប្រាកដថា **វត្តមណីរតនារាម** រហូតមកដល់សព្វថ្ងៃ។

# ហេតុនាំឱ្យកើតគំនិត
# កសាងព្រះបទុមចេតិយ

ក្រោយពេលបានទៅទស្សនកិច្ច និងថ្វាយបង្គំ**បូជនីយដ្ឋាន**ដ៏ច្រើននៅបណ្ដាប្រទេសមួយចំនួន ដូចជា **ឥណ្ឌា នេប៉ាល់ ភូមា** ជាដើម ខ្ញុំក៏មានគំនិតចង់ឱ្យមាន**បូជនីយដ្ឋាន**នៅក្នុងស្រុកខ្មែរយើង សម្រាប់ពុទ្ធបរិស័ទដែលខ្វះលទ្ធភាពក្នុងការធ្វើដំណើរទៅប្រទេសដទៃ បានគោរពបូជាដូចនៅស្រុកគេដែរ។ គាប់ចួនក្នុងឆ្នាំ២០០៥ មហាឧបាសិកា **ញ៉ឹក ប៊ុនថា** មាន**ព្រះសារីរិកធាតុ**ពីរអង្គ **ព្រះធាតុ**មួយអង្គ តម្កល់ក្នុង**ព្រះចេតិយវត្តនិគ្រោធវ័នគល់ទទឹង** មួយអង្គទៀត ជា**ព្រះធាតុ**ខ្នាតតូចបានប្រគល់មកឱ្យខ្ញុំ។ ខ្ញុំក៏បានទទួលនូវ**ព្រះសារីរិកធាតុ** ខ្នាតតូចអង្គនោះមកតម្កល់ទុកក្នុងកុដិធំនៃ**វត្តមណីរតនារាម** ដោយបានរៀបចំ**ព្រះកោដ្ឋ** និងគ្រឿងសក្ការៈផ្សេងៗ គួរជាទីជ្រះថ្លា។ ក្រោយមកដោយគិតថា **ព្រះសារីរិកធាតុ** គឺជាវត្ថុមានតម្លៃក្រៃលែងគួរតែមាន**ព្រះចេតិយ**ដ៏ស្អាត និងធំគួរសមសម្រាប់តម្កល់ទុកជាទីគោរពបូជានៃសាធុជនមកពីគ្រប់មជ្ឈដ្ឋាន។

គ្រានោះ ខ្ញុំមានបំណងកសាង**ព្រះសក្យមុនីចេតិយ** ដែលមានទម្រង់ដូច**ព្រះសក្យមុនីចេតិយ**នៅភ្នំព្រះរាជទ្រព្យ ដែលដឹកនាំកសាងដោយ**អតីតព្រះមហាក្សត្រ** គឺ**ព្រះបាទ នរោត្តម សីហនុ** គ្រាន់តែមានទំហំតូចជាង ប៉ុន្តែ**ស្ថាប័នសម្ដេចព្រះសង្ឃរាជ** បានចេញសេចក្ដីហាមប្រាមមិនអនុញ្ញាតឱ្យកសាង**ព្រះសក្យមុនីចេតិយ**ផ្សេងទៀត ដោយ

បារម្ភថា  អាចនឹងធ្វើឱ្យថយតម្លៃនៃ**ព្រះសក្យមុនីចេតិយ**ដើម  ដូច្នេះ ខ្ញុំក៏បញ្ឈប់នូវគំនិតនេះ ប៉ុន្តែបំណងដែលចង់បង្កើតឱ្យមាន**ព្រះចេតិយ**ដ៏ស័ក្តិសមនឹង**ព្រះសារីរិកធាតុ** នៅតែមានក្នុងចិត្តជានិច្ច។



ព្រះសក្យមុនីចេតិយនៅភ្នំព្រះរាជទ្រព្យ

ពីមួយថ្ងៃទៅមួយថ្ងៃ  ក្រៅពីការបង្រៀន**ធម៌វិន័យ**  ខ្ញុំតែងតែគូសវាសនៅលើក្រដាសផង  លើដីផង  ដោយគិតថា  ធ្វើយ៉ាងណាហ្ន៎ ទើបអាចកសាង**ព្រះចេតិយ**មួយដ៏ល្អ  ដែលមិនផ្ទុយនឹងការហាមប្រាម របស់**សម្តេចព្រះសង្ឃរាជ**ផង  ហើយក៏មិនចង់ចម្លងរចនាបថអំពីបរទេសណាមួយផង។

~ ៥ ~

# បុព្វហេតុនៃការកសាងព្រះបទុមចេតិយ

*ថ្ងៃមួយ លោកគ្រូ **សោម សុភា** (ជាអ្នកគំនូរច្រើនឆ្នាំមកហើយ) បាននាំខ្ញុំទៅមើល**ព្រះពុទ្ធរូប**ទ្រង់ឈរលើផ្កាឈូក ដែលជាការសាកល្បងសូនរូបដំបូងរបស់គាត់ នៅ**វត្តពាលញែក** ក្រុង**ពោធិ៍សាត់**។*



ព្រះពុទ្ធរូបនៅវត្តពាលញែក

*ក្នុងខណៈកំពុងមើលនោះ ខ្ញុំហាក់មិនបានចាប់អារម្មណ៍នឹង**ព្រះពុទ្ធរូប**ទេ បែរជាយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើ**ផ្កាឈូកទ្រព្រះបាទព្រះអង្គ**ទៅវិញ មើលបណ្ដើរគិតបណ្ដើរថា ធម្មតា**ព្រះចេតិយ**ឧទ្ទិសចំពោះ**ព្រះសម្មាសម្ពុទ្ធ** តែងត្រូវបានសាងសង់នៅលើភ្នំឬទីដីខ្ពស់ ចំណែក**វត្តមណីរតនារាម** ស្ថិតនៅទីទំនាបមិនសមគួរជាកន្លែង សម្រាប់សាងសង់**ព្រះសក្យមុនីចេតិយ**ពិតមែន ប៉ុន្តែបើ**ចេតិយ**ផុសឡើងនៅលើផ្កាឈូកពិតជាសមខ្លាំងណាស់ ទោះជាក្នុងត្រពាំងឬបឹងក៏សមដែរ។*



*ភិក្ខុវជិរប្បញ្ញោ **សាន សុជា** ព្រាងប្លង់ព្រះបទុមចេតិយ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៨*

ពេលត្រលប់មកវិញ ក្នុងយប់នោះខ្ញុំមិនបានសម្រាកទេ ខ្ញុំបានគូរព្រាងប្លង់**ព្រះចេតិយ**ដល់ទៅបីបែបផ្សេងៗគ្នា ដែល**ព្រះចេតិយ**នីមួយៗ សុទ្ធតែឈរលើផ្កាឈូក ខ្លះនៅក្នុងទឹក ខ្លះនៅលើគោក និងមានរាងខុសៗគ្នា ដោយដាក់ឈ្មោះថា “**ព្រះបទុមចេតិយ**”។ លុះព្រឹកឡើង ខ្ញុំបង្ហាញដល់ពុទ្ធបរិស័ទឱ្យជួយមើល និងជ្រើសរើសថាមួយណាល្អជាងគេ មតិភាគច្រើនបានជ្រើសយករូបដែលបានភ្ជាប់មកជាមួយនេះឯង និងក្រោយមកលោកគ្រូ **សោម សុភា** ក៏បានជួយសម្រួលឱ្យកាន់តែមានសោភណភាពប្រសើរឡើងៗ

✍📖👓

- ៧ -

# អ្នកជំរុញឱ្យចាប់ផ្ដើម ការសាងសង់ព្រះបទុមចេតិយ

ថ្វីដ្បិតថាគម្រោងបួងបានសម្រេចហើយក៏ពិតមែន ប៉ុន្តែធនធានសម្រាប់ការសាងសង់មិនមានទាល់តែសោះ គឺខ្វះទាំងថវិកា ខ្វះទាំងជាងដែលមានបទពិសោធន៍ ក្នុងការសាងសង់នូវសំណង់ដ៏ធំបែបនេះ។ ការស្ទាក់ស្ទើរក្នុងចិត្តចេះតែបន្តអស់ជាច្រើនខែ ប៉ុន្តែស្របពេលនោះ លោកឪពុករបស់ខ្ញុំ (ឧបាសក **សាន ទុយ**) ចេះតែជំរុញឱ្យខ្ញុំសម្រេចចិត្តចាប់ផ្ដើម ប៉ុន្តែខ្ញុំនៅតែរកពន្លឺនៃការចាប់ផ្ដើមមិនបាន។



ថ្ងៃមួយលោកឪពុកបានសន្ទនាជាមួយខ្ញុំ ដោយផ្ដើមថា៖

**ឪពុក** : លោកកូន តើគិតចាប់ផ្ដើមកសាងពេលណា?

**ខ្ញុំ** : មិនដឹងចាប់ផ្ដើមដោយវិធីណាទេញោម ព្រោះគ្មានអ្វីបន្តិចផង

**ឪពុក** : មើលតាមរូប**ព្រះបទុមចេតិយ**នេះ ត្រូវកសាងនៅក្នុងស្រះឬ?

**ខ្ញុំ** : ពរ ត្រូវហើយញោម

**ឪពុក** : ចុះបើញោមអាចរកអ្នកចេញថ្លៃជីកស្រះបាន តើលោកកូនឱ្យជីកឬទេ?

**ខ្ញុំ** : មិនអីទេញោម បើញោមរកអ្នកឧបត្ថម្ភបាន ញោមជីកចុះ។

ក្រោយមកមិនយូរប៉ុន្មាន **លោកឪពុក**ក៏រកអ្នកចេញថ្លៃជីកស្រះបានមែន គឺលោកយាយឧបាសិកា **យុត តាំងអ៊ិន**។



ជិះលើរទេះរុញ គឺឧបាសិកា **យុត តាំងអ៊ិន** អ្នករុញគឺ ឧបាសក **សាន ទុយ**

ព្រោះដូច្នោះ ខ្ញុំហាក់មានចិត្តត្រេកអរដែរ ក៏បានយករឿងនេះទៅពិភាក្សាជាមួយលោកគ្រូ **សោម សុភា** ពេលនោះគាត់មិនមាន យោបល់អ្វីច្រើនទេ និងបានឯកភាពឱ្យជីក ដោយបានបន្ថែមពាក្យ បែបជាការលេងសើចផងថា ទោះជារកលុយកសាង**ព្រះបទុមចេតិយ** មិនបានយ៉ាងហោចក៏បានស្រះទឹកមួយដែរ។ ការនិយាយបែបនេះ ក្នុងគំនិតរបស់គាត់កាលនោះយល់ថា **ព្រះបទុមចេតិយ**នេះ គឺមាន តែក្នុងគំនូរប៉ុណ្ណោះ មិនអាចកើតឡើងបានទេ ហើយបើទោះជា កើតឡើង គាត់ក៏មិនមែនជាជាងទទួលបន្ទុកសាងសង់ដែរ។

✍📖👓

~ ៩ ~

# ការរៀបគម្រោងសាងសង់ ព្រះបទុមចេតិយ

*ក្រោយពេលជីកស្រះរួច ខ្ញុំបានអញ្ជើញលោកគ្រូ* ***សោម សុភា*** *មកពិភាក្សាពីការសាងសង់****ព្រះបទុមចេតិយ****។ ពេលនោះគាត់ហាក់ដូចជាភ្ញាក់ថា "អូ! គិតចង់ឱ្យខ្ញុំកូរណាជាអ្នកសាងសង់មែនទែន! ខ្ញុំកូរណាជាជាងគំនូរសោះហ្នឹង! ខ្ញុំកូរណាគិតថា លោកម្ចាស់មិនធ្វើទេ ហើយបើធ្វើក៏មិនមែនយកខ្ញុំកូរណាធ្វើជាជាងដែរ"។ ខ្ញុំតបថា "មានជាងឯណាទៀត មូលហេតុដែលនាំឱ្យអាត្មាគូរប្លង់នេះ ក៏ដោយសារញោមដែរ"។*



*រូបស្រះដែលទើបតែជីករួច ឧបត្ថម្ភដោយឧបាសិកា* ***ឃុត តាំងអ៊ិន***

*ថ្វីដ្បិតថាមិនដឹងចាប់ផ្ដើមដោយវិធីណា ប៉ុន្តែក៏មិនអស់សង្ឃឹមដែរ ខ្ញុំបានគិតថា បានព្រះចន្ទគង់គេអាចទៅដល់ ចុះត្រឹមតែសាងសង់*

របស់នៅលើដីសោះ រឿងអ្វីដែលថាធ្វើមិនបាន ប៉ុន្តែក៏មិនចេះតែហ៊ាន ធ្វើទាំងដែលមិនដឹងអ្វីសោះនោះដែរ។ ចាប់ពីពេលនោះមកខ្ញុំនិង លោកគ្រូ **សោម សុភា** តែងតែពិភាក្សាគ្នា ដើម្បីស្វែងរកច្រកចេញ។ សំណាងល្អ បានជួបលោក **ទាង ប៉ុនរី** ដែលជាអ្នកជំនាញខាង សំណង់ប្រចាំ**ខេត្តពោធិ៍សាត់** គាត់បានស្ម័គ្រចិត្តគូរប្លង់ពង (ឬប្លង់ គ្រោងឆ្អឹងសំណង់) ដោយឥតគិតថ្លៃ។ ក្រៅពីការជួយគូរប្លង់ លោក **ទាង ប៉ុនរី** នៅតាមជួយពិនិត្យគុណភាពសំណង់ផងដែរ និងមានវិស្វករ ស្ម័គ្រចិត្តជាច្រើនរូបទៀត ដែលជួយតាមដាន។



*នេះជាប្លង់ឆ្អឹងដំបូងដែលគូរដោយលោក **ទាង ប៉ុនរី** ប៉ុន្តែក្រោយមកបានកែសម្រួលខ្លះ*

~ ១១ ~

ក្រោយពីបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់ ខ្ញុំបានកោះប្រជុំគណៈកម្មការ អាចារ្យ ដើម្បីពិភាក្សាអំពីគម្រោងសាងសង់នេះ ហើយក៏បានឯកភាពគ្នាថានឹងចាប់ផ្ដើមចាក់គ្រឹះ **ព្រះបទុមចេតិយ** ដោយពិតប្រាកដ។

# ការចាប់ផ្ដើមសាងសង់ ព្រះបទុមចេតិយ

*ក្រោយពីការពិភាក្សាយ៉ាងល្អិតល្អន់ ការចាក់គ្រឹះ**ព្រះបទុមចេតិយ** ក៏បានចាប់ផ្ដើម គឺនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៩។ ព្រះសង្ឃ និងពុទ្ធបរិស័ទនៃ**វត្តមណីរតនារាម** បានរួមគ្នាប្រារព្ធកម្មវិធីបញ្ចុះ**បឋមសិលា** ដោយសេចក្ដីជ្រះថ្លារីករាយក្រៃលែង។*



*ការកសាងនេះ គ្មានប្រាក់បម្រុង ហើយក៏គ្មានការរៃអង្គាសដែរ ព្រោះគោលការណ៍សំខាន់នៃការបង្កើត**វត្តមណីរតនារាម** មានវត្ថុបំណងសំខាន់បំផុត គឺបង្កលក្ខណៈឱ្យមានការសិក្សា**ព្រះធម៌ ព្រះវិន័យ** និង**គោរពប្រតិបត្តិ**ដោយសេចក្ដីជ្រះថ្លា រីឯសមិទ្ធផលផ្សេងៗ សូម្បីតែព្រះ**បទុមចេតិយ**នេះ គឺជាសមិទ្ធផលដែលប្រសូតចេញពីការជ្រះថ្លា*

ក្នុង**ព្រះធម៌**នៃពុទ្ធបរិស័ទដែលបានស្ដាប់ហើយ និងសិក្សាហើយ ប៉ុណ្ណោះ គឺថា ពុទ្ធបរិស័ទដែលចូលរួមក្នុងការសាងសង់នូវ**ព្រះបទុមចេតិយ**នេះ សុទ្ធតែបានស្ដាប់ព្រះធម៌ជាមុនរួចមកហើយ។





~ ១៤ ~

# ការបង្កើតកម្លាំងពិត

ថ្វីដ្បិតថា ការចាក់គ្រឹះ**ព្រះបទុមចេតិយ**បានចាប់ផ្តើមក៏ពិតមែន ប៉ុន្តែក្រុមជាងដែលយើងរកមកធ្វើដំបូង ហាក់មិនបានយល់ចិត្តថ្លើមគ្នា ធ្វើឱ្យដំណើរការនៃការសាងសង់មានភាពរអាក់រអួលខ្លះ ខ្ញុំក៏បានលើកយកបញ្ហានេះ មកពិភាក្សានឹងលោកគ្រូ **សោម សុភា**។ លោកគ្រូ **សោម សុភា** បានមានប្រសាសន៍ថា "យើងគួរតែមានក្រុមកម្លាំងពិតរបស់យើង ដែលយើងអាចបណ្តុះបណ្តាល និងចាត់ចែងបាន"។ ស្របពេលនោះ លោកគ្រូ **សោម សុភា** កំពុងមានបំណងចង់បង្កើត**សមាគម**មួយ ដែលផ្តោតលើការបណ្តុះបណ្តាល**វិស័យវប្បធម៌** ពិសេសគឺគំនូរនិងចម្លាក់ជាដើម ខ្ញុំក៏បានឧបត្ថម្ភកិច្ចការនោះ ធ្វើយ៉ាងណាឱ្យ**សមាគម**របស់គាត់បានកើតឡើងដោយស្របច្បាប់។ មិនយូរប៉ុន្មាន **សមាគម**របស់គាត់ក៏បានកើតឡើង ដោយមានឈ្មោះថា **សមាគមសិល្បៈសូនរូបខ្មែរ** ដែលមាន លោកគ្រូ **សោម សុភា** ជាប្រធានប្រតិបត្តិ។



ចាប់ពីពេលនោះមក **សមាគម**មួយនេះ បានចាប់ផ្តើមបណ្តុះបណ្តាលយុវជនជាច្រើន ហើយ**ព្រះបទុមចេតិយ**ក៏ក្លាយជាសាលារៀនរបស់ប្អូនៗ នៅក្នុង**សមាគម**រហូតមក។



សរុបមក **ព្រះបទុមចេតិយ** នេះ ផ្ដើមចេញពីគំនិតថ្មី មិនបាន ចម្លងពីសំណង់ចាស់ណាមួយឡើយ អ្នកផ្ដើមគំនិតកសាងក៏ថ្មី **ក្រុមជាង**ក៏ថ្មី គឺសុទ្ធតែជាការសិក្សាថ្មីទាំងអស់ ទើបមានរូបរាងខុសគេបែបនេះ។





ក្នុងដំណើរការនៃការសាងសង់នេះ លោក **ឈិត កេត** ក៏បាន ចូលរួមក្នុងការពិនិត្យមើលគុណភាពសំណង់រហូតមកផងដែរ។ ជាមួយគ្នានោះ ព្រះសង្ឃ អាចារ្យ គណៈកម្មការវត្តក៏បានចូលរួមយ៉ាងសស្រាក់សស្រាំ ពុទ្ធបរិស័ទពីមជ្ឈដ្ឋាននានា ក៏ផ្ដើមឧបត្ថម្ភរហូតមក។

~ ១៧ ~

# រូបភាពបង្ហាញពីដំណើរការនៃការកសាង



*ថ្ងៃសុក្រ ទី០៥ ខែមិថុនា ឆ្នាំ២០០៩*



*ថ្ងៃអង្គារ ទី១៦ ខែមិថុនា ឆ្នាំ២០០៩*



ថ្ងៃព្រហស្បតិ៍ ទី០២ ខែមេសា ឆ្នាំ២០០៩



ថ្ងៃព្រហស្បតិ៍ ទី០៩ ខែមេសា ឆ្នាំ២០០៩



ថ្ងៃពុធ ទី១៩ ខែកក្កដា ឆ្នាំ២០០៩



ថ្ងៃពុធ ទី០៧ ខែមេសា ឆ្នាំ២០១០



ថ្ងៃអាទិត្យ ទី០៩ ខែមករា ឆ្នាំ២០១១



ថ្ងៃព្រហស្បតិ៍ ទី២៤ ខែមេសា ឆ្នាំ២០១២



មិនច្បាស់កាលបរិច្ឆេទ



ថ្ងៃពុធ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣



ថ្ងៃពុធ ទី១៤ ខែឧសភា ឆ្នាំ២០១៤



ថ្ងៃពុធ ទី០៣ ខែឧសភា ឆ្នាំ២០១៥



ថ្ងៃអាទិត្យ ទី១៩ ខែឧសភា ឆ្នាំ២០១៦



ថ្ងៃអង្គារ ទី២០ ខែឧសភា ឆ្នាំ២០១៧



ថ្ងៃពុធ ទី២០ ខែឧសភា ឆ្នាំ២០១៨



ថ្ងៃអាទិត្យ ទី២៨ ខែតុលា ឆ្នាំ២០១៨



ថ្ងៃព្រហស្បតិ៍ ទី២០ ខែឧសភា ឆ្នាំ២០១៩



ថ្ងៃអាទិត្យ ទី០៧ ខែឧសភា ឆ្នាំ២០២០



ថ្ងៃចន្ទ ទី១៩ ខែកញ្ញា ឆ្នាំ២០២២



*ថ្ងៃអាទិត្យ ទី១៥ ខែតុលា ឆ្នាំ២០២៣*



*កិច្ចប្រជុំការងារវត្តមណីរតនារាមប្រចាំខែ*

✍📖👓

~ ២៨ ~

# ការបញ្ចប់កិច្ចការដែលសេសសល់

ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៦ ខ្ញុំបានមករស់នៅ**ប្រទេសអូស្ត្រាលី** ប៉ុន្តែតួនាទីជា**ព្រះចៅអធិការវត្ត**នៅតែបន្ត ម្ល៉ោះហើយការគ្រប់គ្រងវត្តក៏នៅតែបន្តពីចម្ងាយដែរ ដោយមាន**ព្រះគ្រូសូត្រ**ឆ្វេងស្តាំ និង**អាចារ្យ គណៈកម្មការ** ជាអ្នកចាត់ចែងការងារជំនួសដោយផ្ទាល់។

ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣ ខ្ញុំបានលាចាក**សិក្ខា** ខ្ញុំបានប្រគល់កិច្ចការវត្តទាំងស្រុង ប្រគេន និងជូន**គណៈគ្រប់គ្រងវត្ត** ដែលមានលោកម្ចាស់គ្រូ **លទ្ធធម្មោ ជា គឹមសាន** ដែលទើបឡើងជា**ព្រះចៅអធិការ**ថ្មី ជាប្រធាន ហើយលោកគឺជាអ្នកទទួលការងារបន្តវេនអំពីខ្ញុំ ដោយលោកជាអ្នកមើលការខុសត្រូវក្នុងការងារសេសសល់មួយចំនួន ដូចជាការក្រាលកម្រាលឥដ្ឋជុំវិញ**ព្រះបទុមចេតិយ**ជាដើម រហូតមកដល់សព្វថ្ងៃ។



រូបថតចុងក្រោយក្នុង**វត្តមណីរតនារាម** ក្នុងភាពជា**ភិក្ខុវជិរប្បញ្ញោ សាន សុជា** ឆ្នាំ២០២២

# អត្ថន័យសំខាន់ៗ អំពីព្រះបទុមចេតិយ




ការស្តាប់ ឬទស្សនាអ្វីមួយ មិនអាចធ្វើឱ្យចិត្តរីករាយពេញលេញដោយគ្រាន់តែឮ ឬឃើញប៉ុណ្ណោះទេ ឧទាហរណ៍ដូចជាការទស្សនាខ្សែភាពយន្ត ឬកីឡា គឺទាល់តែយល់នូវអត្ថន័យ ឬកតិកាក្នុងរឿងរ៉ាវទាំងនោះផង ទើបកាន់តែសប្បាយរីករាយក្នុងការទស្សនាដូចគ្នានេះដែរ ការបានឃើញ ឬថ្វាយបង្គំ**ព្រះបទុមចេតិយ**នេះ បើយល់អត្ថន័យ និងគោលបំណងនៃការកសាងផងនោះ ចិត្តអ្នកថ្វាយបង្គំនឹងកាន់តែជ្រះថ្លាទ្វេឡើង ដូច្នេះខ្ញុំនឹងធ្វើការអត្ថាធិប្បាយ នូវចំណុចសំខាន់ៗ នៃ**ព្រះបទុមចេតិយ** ដូចតទៅ៖

## ១- ឧទ្យានជុំវិញព្រះបទុមចេតិយ

ទីធ្លាដែលមានស្រះ និងអាងទឹក លម្អដោយសួនផ្កាចម្រុះ តំណាងឱ្យ**ជម្ពូទ្វីប**ទាំងមូល ដែលបរិបូណ៌ដោយ**ធនធានធម្មជាតិ** ស្រស់ត្រកាលលើស**ភព**ណាៗទាំងអស់អាចផ្តល់ទីជម្រក ចំណី អាហារ ខ្យល់ដង្ហើមសម្រាប់ជីវិតនៃមនុស្ស សត្វ រាប់លានកោដិឆ្នាំ និងរាប់ចំនួនមិនបាន។ ដូច្នេះ អ្នកមកទស្សនា ឬថ្វាយបង្គំនៅទីលាន **ព្រះចេតិយ**នេះ គួរបង្កើននូវសេចក្តីស្រឡាញ់ចំពោះ**ធនធានធម្មជាតិ** ដែលជាអ្វីៗគ្រប់យ៉ាងរបស់យើង គឺគួរចូលរួមថែរក្សា**ធនធានធម្មជាតិ** ដែលមានស្រាប់មិនបំផ្លាញព្រោះបំពេញមហិច្ឆតារបស់ខ្លួន និងចូលរួមបន្តបង្កើនការដាំដុះឱ្យកាន់តែស្រស់បំព្រងឡើង។



ក្នុងប្រវត្តិ**មឃមាណព** (អតីតជាតិរបស់**ព្រះឥន្ទ**) ដែលបានសាងបុណ្យដោយការកសាងផ្លូវ និងសាលាសម្នាក់ជាដើម ក្នុងជាតិនោះ គាត់មានភរិយា ៤ នាក់គឺ នាង**សុធម្មា** ចូលរួមធ្វើហោជាងសាលា នាង**សុនន្ទា**ចូលរួមជីកស្រះទឹកខាងមុខសាលា នាង**សុចិត្រា**ចូលរួមធ្វើសួនច្បារជុំវិញសាលា រីឯភរិយាទី ៤ គឺនាង**សុជាតា** មិនបានសាងបុណ្យអ្វីនឹងគេទេ ដោយគិតថា "ទ្រព្យដែលប្តីរបស់អញមាន ក៏ដូចជារបស់អញ បុណ្យរបស់ប្តីក៏ដូចជារបស់អញដែរ ដូច្នេះអញមិនចាំបាច់ធ្វើអ្វីទេ គិតតែតែងខ្លួនឱ្យស្អាតតម្រូវចិត្តប្តីវិញ"។ លុះអ្នកទាំងអស់គ្នាធ្វើមរណកាលពីជាតិនោះ **មឃមាណព**បានមកជា**ព្រះឥន្ទ** ភរិយាទី ១ ទី ២ និងទី ៣ ក៏បានមកជា**ទេពធីតា**ក្នុង**ឋានតាវត្តិង្ស**ជាមួយនឹង**ព្រះឥន្ទ**ដែរ ចំណែកនាង**សុជាតា** បានកើតជាកុកញីក្នុងជ្រលងភ្នំដ៏ស្ងាត់តែម្នាក់ឯង (ក្រោយមកបានការណែនាំពី**ព្រះឥន្ទ** ក៏ខំសន្សំបុណ្យ បន្ទាប់ពីស្លាប់បានកើតជាមនុស្ស រួចកើតជាកូន**ស្តេចអសុរ** និងបានជា**មហេសី**របស់**ព្រះឥន្ទ** រហូតមក)។

ការថែរក្សា និងការដាំដុះ**ធនធានធម្មជាតិ** គឺជាការសាងបុណ្យដ៏ធំសម្រាប់ខ្លួនយើងផង សម្រាប់មនុស្សសត្វទូទៅផង។ រុក្ខជាតិដែលយើងដាំដុះ តែងក្លាយជាទីជម្រកនៃមនុស្សម្នា និងសត្វតូចធំដ៏ច្រើន ដើមឈើខ្លះមានអាយុវែងជាងអ្នកដាំទៅទៀត។ ម្យ៉ាងទៀត រូបរាងកាយរបស់យើងសុទ្ធតែផ្តុំឡើងអំពីធម្មជាតិ ដូច្នេះទើបមិនគួរបំផ្លាញប្រកពរស់របស់យើងឡើយ។

## ២- បដិមាព្រះអសីតិមហាសាវក ៨០ អង្គ

*__រូបបដិមា__ទ្រង់ឈរនៅជុំវិញ និងបែរព្រះភក្ត្រទៅកាន់ __ព្រះបទុមចេតិយ__ ជារូបតំណាង__ព្រះអសីតិមហាសាវក__ គឺសាវកធំៗ ទាំង ៨០ អង្គរបស់__ព្រះសម្មាសម្ពុទ្ធ__ ដែលមួយអង្គៗ មានកូនសិស្សជាភិក្ខុសង្ឃយ៉ាងហោច ៥០០ អង្គ ដូច្នេះភិក្ខុសង្ឃដែលជាកូនសិស្សនៅក្រោមឱវាទនៃ__ព្រះអសីតិមហាសាវក__ទាំងនោះ មានរាប់ម៉ឺនអង្គឯណោះ។*



*ការផ្សព្វផ្សាយ__ព្រះធម៌ ព្រះវិន័យ ព្រះសម្មាសម្ពុទ្ធ__មិនមែនធ្វើតែមួយអង្គឯងនោះទេ គឺ__ព្រះអង្គ__បានចែកការងារដល់__សាវករបស់ព្រះអង្គ__ឱ្យចូលរួមធ្វើ ហើយការចូលរួមនេះទៀតសោត សុទ្ធតែកើតចេញពីសេចក្តីជ្រះថ្លា បូជាសូម្បីជីវិត ដោយមិនទាមទារការតបស្នងនូវមាសប្រាក់ ឋានៈ យសស័ក្តិអ្វីទាំងអស់។ នេះបង្ហាញឱ្យឃើញថា __ព្រះសម្មាសម្ពុទ្ធ__ គឺជាកំពូលអ្នកដឹកនាំ ដោយមិនចាំបាច់ប្រើមាសប្រាក់ ឋានៈ យសស័ក្តិ ឬរង្វាន់ផ្សេងៗ ទៅទាក់ទាញទឹកចិត្តមនុស្សនោះទេ ព្រះអង្គបង្ហាញតែមាគ៌ាសម្រាប់ប្រតិបត្តិដ៏ត្រឹមត្រូវក្នុងជីវិតប៉ុណ្ណោះ។*

ក្នុងនាមយើងជា**ពុទ្ធបរិស័ទ** ពេលឃើញ **ព្រះអសីតិមហាសាវក** ទាំង ៨០ អង្គនេះ គួរបង្អោនចិត្តថ្វាយបង្គំដោយចាត់ទុកថា លោកទាំងនោះ គឺជារៀមច្បងក្នុង**ធម៌វិន័យ**របស់យើង ព្រោះលោកគឺជាធនធានដ៏អស្ចារ្យ ក្នុងការញ៉ាំងពន្លឺនៃ**ព្រះសទ្ធម្ម** ឱ្យចែងចាំងឡើងក្នុង**សកលជម្ពូទ្វីប**។

## ៣- ផ្កាឈូកទ្រព្រះចេតិយ

***ផ្កាឈូកទ្រព្រះចេតិយ**ដ៏ធំនេះ តំណាងឱ្យភាពផូរផង់នៃជនគ្រប់គ្នាដែលបានយល់ត្រូវ និងប្រព្រឹត្តល្អ **ព្រះពុទ្ធបរមគ្រូ**បានដាក់នាមថា **បទុមឧបាសក រតនឧបាសក** ឬ**បុណ្ឌរីកឧបាសក**។*



## ឧបាសក ឧបាសិកាមិនល្អ
## ព្រោះប្រកបដោយគុណវិបត្តិ ៥ យ៉ាង

*ក្នុង**ព្រះត្រៃបិដកលេខ** ៤៥ ទំព័រទី ១៥៥ **ព្រះមានព្រះភាគ**ទ្រង់សម្តែងអំពី**វិបត្តិ**របស់**ឧបាសក ឧបាសិកា** ដោយសេចក្តីថា ម្នាលភិក្ខុទាំងឡាយ **ឧបាសក** (ក្នុងនោះក៏មាន**ឧបាសិកា**ដែរ) ប្រកបដោយ**ធម៌** ៥ យ៉ាង ឈ្មោះថា **ចណ្ឌាលឧបាសក** (អន់ ទន់ទាប ឬកោងកាច) ផង ឈ្មោះថា **មលឧបាសក** (មានមន្ទិល ឬមិនស្អាតស្អំ) ផង ឈ្មោះថា **បដិកិដ្ឋឧបាសក** (គួរខ្ពើម) ផង។ **ធម៌** ៥ យ៉ាង តើដូចម្តេច គឺ៖*

*ក- **អស្សទ្ធោ ហោតិ** ជាអ្នកមិនមានសទ្ធា ១*

ខ- ***ទុស្សីលោ ហោតិ*** ជាអ្នកទ្រុស្តសីល ១

គ- ***កោតុហលមង្គលិកោ ហោតិ*** ប្រកាន់ (ជឿ) មង្គលភ្ញាក់ផ្អើល ១

ឃ- ***មង្គលំ បច្ចេតិ នោ កម្មំ*** ជឿតែមង្គល មិនជឿលើកម្ម ១

ង- ***ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ*** ស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅពុទ្ធសាសនា ហើយធ្វើបុណ្យនឹងទក្ខិណេយ្យបុគ្គលនោះ ១។

## ឧបាសក ឧបាសិកាល្អ
## ព្រោះប្រកបដោយគុណសម្បត្តិ ៥ យ៉ាង

***ព្រះសម្មាសម្ពុទ្ធ***ទ្រង់សម្ដែងបន្តទៀតថា ម្នាលភិក្ខុទាំងឡាយ ***ឧបាសក***ប្រកបដោយ***ធម៌*** ៥ យ៉ាង ឈ្មោះថា ***រតនឧបាសក*** (កែវមានតម្លៃ) ផង ឈ្មោះថា ***បទុមឧបាសក*** (ផ្កាឈូកក្រហម) ផង ឈ្មោះថា ***បុណ្ឌរីកឧបាសក*** (ផ្កាឈូកស) ផង។ ***ធម៌*** ៥ យ៉ាង តើដូចម្ដេច គឺៈ

ក- ***សទ្ធោ ហោតិ*** ជាអ្នកមានសទ្ធា ១

ខ- ***សីលវា ហោតិ*** អ្នកមានសីល ១

គ- ***អកោតុហមង្គលិកោ ហោតិ*** ជាអ្នកមិនប្រកាន់ (គឺមិនជឿ) មង្គលភ្ញាក់ផ្អើល ១

ឃ- ***កម្មំ បច្ចេតិ នោ មង្គលំ*** ជឿតែកម្ម មិនជឿមង្គល ១

ង- ***ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វករំ ករោតិ*** មិនស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅពុទ្ធសាសនា ធ្វើបុណ្យតែក្នុងពុទ្ធសាសនានេះ ១។

**ផ្កាឈូក** គឺជាផ្កាដែលដុះចាកពីទីទឹក និងភក់ ជាកន្លែងមិនស្អាត ប៉ុន្តែពេល**ផ្កាឈូក**លូតផុតទឹកកាលណា ក៏ក្លាយជាផ្កាបរិបូណ៌ដោយពណ៌ និងក្លិន មិនប្រឡាក់ដោយមន្ទិលផ្សេងៗឡើយ យ៉ាងណាមិញ **ពុទ្ធបរិស័ទ**ទាំងឡាយ ទោះជាមកពី**គ្រួសារ ឬវណ្ណៈ**ខុសគ្នា ឬក៏អន់ថយយ៉ាងណាក៏ដោយ ឱ្យតែមានការសិក្សារៀនសូត្រ យល់ដឹងនូវហេតុផល មាន**គុណសម្បត្តិទាំង** ៩ ដូចខាងលើ សុទ្ធតែអាចក្លាយជា**បទុមឧបាសក បទុមឧបាសិកា**បានទាំងអស់។ ហើយឈ្មោះនេះ នរណាៗ ក៏មិនអាចសុំបានដែរ គឺវាកើតឡើងដោយស្វ័យប្រវត្តិ ព្រោះអាស្រ័យលើការយល់ដឹង និងការប្រព្រឹត្តតែប៉ុណ្ណោះ។ ខ្ញុំសង្ឃឹមថា **ពុទ្ធបរិស័ទ**ដែលបានមកថ្វាយបង្គំនូវ**ព្រះបទុមចេតិយ**នេះ អាចបានយល់អំពីអត្ថន័យ និងក្លាយជា **បទុមឧបាសក បទុមឧបាសិកា** គ្រប់ៗគ្នា។

## ៤- ព្រះសាវក ៦០ អង្គ

ផ្នែកខាងលើផ្កាឈូកដ៏ធំ មានតម្កល់**សង្ឃបដិមា**ចំនួន ៦០ អង្គ តំណាង**ព្រះសាវក**ដំបូងរបស់**ព្រះសម្មាសម្ពុទ្ធ**។

ក្នុងវស្សាទី ១ បន្ទាប់ពីបានត្រាស់ដឹង **ព្រះអង្គ**ទ្រង់គង់នៅក្នុងព្រៃ**ឥសិបតនមិគទាយវ័ន** ជិតក្រុង**ពារាណសី**។ ក្នុងទីនោះឯង **ព្រះអង្គ**ទ្រង់ចាប់ផ្ដើមសម្ដែង**ព្រះធម្មចក្កប្បវត្តនសូត្រ** ប្រោស**បញ្ចវគ្គិយ៍**ចំនួន ៥ អង្គ មាន**ព្រះអញ្ញាកោណ្ឌញ្ញៈ**ជាដើម ដែលជា**បឋមទេសនា**របស់**ព្រះអង្គ**។ ក្នុងវស្សាទី ១ ដដែលនេះ **យសកុលបុត្រ**មួយអន្លើដោយសម្លាញ់របស់ខ្លួន ៥៤ នាក់ បានទៅបួសក្នុងសម្នាក់**ព្រះអង្គ** មិនយូរប៉ុន្មានក៏បានសម្រេចជា**ព្រះអរហន្ត**ទាំងអស់ ដូច្នេះ**បញ្ចវគ្គិយ៍** ៥ អង្គ រួមជាមួយនឹង**ព្រះយស** និងសម្លាញ់របស់លោក ៥៤ អង្គផង ត្រូវជា ៦០ អង្គ។



ក្រោយចេញវស្សា **ព្រះមានព្រះភាគ**ទ្រង់បញ្ជូននូវ**ព្រះអរហន្ត**ទាំង ៦០ អង្គនោះ ឱ្យនាំយក**ព្រះធម៌**ទៅសម្ដែងពន្យល់ដល់មនុស្ស

ទាំងឡាយ ដោយ**ព្រះពុទ្ធតម្រាស់**ថា "ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយត្រាច់ចារិកទៅ ដើម្បីប្រយោជន៍ ដើម្បីអនុគ្រោះដល់ពួកជនដ៏ច្រើន ដើម្បីអនុគ្រោះសត្វលោក ដើម្បីសេចក្ដីសុខដល់**ទេវតា**និង**មនុស្ស**ទាំងឡាយ អ្នកទាំងឡាយចូរកុំទៅផ្លូវមួយ ២ រូបឡើយ។ ពួកអ្នកចូរសម្ដែងធម៌ មាន**លម្អបទដើម លម្អបទកណ្ដាល** និង**លម្អបទចុង** ចូរប្រកាស**ព្រហ្មចរិយធម៌** ដោយ**អត្ថ**ព្រមទាំង**ព្យញ្ជនៈ**ដ៏បរិសុទ្ធបរិបូណ៌ សូម្បី**តថាគត**ក៏នឹងទៅកាន់ **ឧរុវេលសេនានិគម** ដើម្បីសម្ដែងធម៌ដែរ"។

ស្របពេលនោះដែរ **ព្រះអង្គ**ទ្រង់អនុញ្ញាតឱ្យ**សាវក**ទាំង ៦០ អង្គនោះ មានសិទ្ធិអាចបំបួសកុលបុត្តបាន ដោយវិធីឱ្យទទួល**ត្រៃសរណគមន៍** គឺការបួសជា**ភិក្ខុភាវៈ**ដោយមាន**ព្រះរតនត្រ័យ**ជា**សរណៈ** ការបួសនេះហៅថា **តិសរណគមនូបសម្បទា**។ ក្រោយមក **ព្រះអង្គ**ទ្រង់អនុញ្ញាតឱ្យព្រះអរហន្តទាំង ៦០ អង្គនោះ មានសិទ្ធិក្នុងការបំបួស**សាមណេរ**ថែមទៀត។

នេះជា**បេសកកម្ម**ដំបូង ក្នុងការផ្សព្វផ្សាយ**ព្រះពុទ្ធសាសនា** ដោយ**ព្រះអរហន្ត**ចំនួន ៦០ អង្គ គឺជា**ព្រះអរហន្ត** ជា**សង្ឃរតនៈ** គួរជាទីគោរពជ្រះថ្លាក្រៃលែង ទើប**ព្រះចេតិយ**នេះ មានរូប**បដិមា**តំណាងទុកជាទីគោរពសក្ការៈ នៃសាធុជនទាំងឡាយអស់កាលជាអង្វែង។

## ៥- ព្រះពុទ្ធ ២៨ ព្រះអង្គ

ផ្នែកខាងលើនៃ**ព្រះសាវក** ៦០ អង្គ មានតម្កល់**ព្រះពុទ្ធរូប** ២៨ **ព្រះអង្គ** រាប់ចាប់ពី**ព្រះសម្មាសម្ពុទ្ធ**ព្រះនាម**តណ្ហង្ករៈ**មក។



ពុទ្ធបរិស័ទដែលបានចូលថ្វាយបង្គំនូវ**ព្រះសម្មាសម្ពុទ្ធ**ទាំង ២៨ ព្រះអង្គ គួរពោលនូវ**ព្រះបរិត្ត**ដូចខាងក្រោម ។

### អាដានាដិយបរិត្ត

### នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះ**ព្រះពុទ្ធ**ជាម្ចាស់គ្រប់**ព្រះអង្គ** ដែលបានត្រាស់រួចមកហើយ **ព្រះអង្គ**ស្វែងរកនូវគុណដ៏ធំ (**ព្រះសម្ពុទ្ធ**ទាំងឡាយនោះគឺ)

១- **តណ្ហង្ករោ មហាវីរោ**      **ព្រះតណ្ហង្ករ**

ព្រះអង្គមានព្យាយាមធំ

| | | |
|---|---|---|
| ២- | មេធង្ករោ មហាយសោ | ព្រះមេធង្ករ<br>ព្រះអង្គមានយសធំ |
| ៣- | សរណង្ករោ លោកហិតោ | ព្រះសរណង្ករ<br>ព្រះអង្គធ្វើឱ្យជាប្រយោជន៍ដល់<br>សត្វលោក |
| ៤- | ទីបង្ករោ ជុតិន្ធរោ | ព្រះទីបង្ករ<br>ព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង |
| ៥- | កោណ្ឌញ្ញោ ជនបាមោក្ខោ | ព្រះកោណ្ឌញ្ញៈ<br>ព្រះអង្គជាប្រធាននៃពពួកជន |
| ៦- | មង្គលោ បុរិសាសភោ | ព្រះមង្គល<br>ព្រះអង្គជាបុរសដ៏ប្រសើរ |
| ៧- | សុមនោ សុមនោ ធីរោ | ព្រះសុមន ព្រះអង្គជាអ្នកប្រាជ្ញ<br>មានព្រះហឫទ័យដ៏ល្អ |
| ៨- | រេវតោ រតិវឌ្ឍនោ | ព្រះរេវត<br>ព្រះអង្គញ៉ាំងសេចក្ដី<br>ត្រេកអរឱ្យចម្រើន |
| ៩- | សោភិតោ គុណសម្បន្នោ | ព្រះសោភិត<br>ព្រះអង្គបរិបូណ៌ដោយព្រះគុណ |
| ១០- | អនោមទស្សី ជនុត្តមោ | ព្រះអនោមទស្សី<br>ព្រះអង្គឧត្តមជាងពពួកជន |
| ១១- | បទុមោ លោកបជ្ជោតោ | ព្រះបទុម |

ព្រះអង្គញ៉ាំងលោកឱ្យភ្លឺស្វាង

១២- នារទោ វរសារថី ព្រះនារទ

ព្រះអង្គដូចជាសារថីដ៏ប្រសើរ

១៣- បទុមុត្តរោ សត្តសារោ ព្រះបទុមុត្តរ

ព្រះអង្គជាខ្លឹមសារ

នៃពួកសត្វ

១៤- សុមេធោ អប្បដិបុគ្គលោ ព្រះសុមេធ

ព្រះអង្គរកបុគ្គលប្រៀបដូចគ្មាន

១៥- សុជាតោ សព្វលោកគ្គោ ព្រះសុជាត

ព្រះអង្គប្រសើរលើស

ជាងសត្វលោកទាំងពួង

១៦- បិយទស្សី នរាសភោ ព្រះបិយទស្សី

ព្រះអង្គប្រសើរជាងនរជន

១៧- អត្ថទស្សី ការុណិកោ ព្រះអត្ថទស្សី

ព្រះអង្គប្រកបដោយករុណា

១៨- ធម្មទស្សី តមោនុទោ ព្រះធម្មទស្សី

ព្រះអង្គបន្ទោបង់នូវងងឹត

១៩- សិទ្ធត្ថោ អសមោ លោកេ ព្រះសិទ្ធត្ថ

ព្រះអង្គឥតមានអ្នកណា

ស្មើក្នុងលោក

២០- តិស្សោ ច វទតំ វរោ ព្រះតិស្ស

ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញ
ខាងសម្តីទាំងឡាយ

២១- ផុស្សោ ច វរទោ ពុទ្ធោ — ព្រះពុទ្ធទ្រង់ព្រះនាមផុស្ស
ព្រះអង្គប្រទាននូវធម៌ដ៏ប្រសើរ

២២- វិបស្សី ច អនូបមោ — ព្រះវិបស្សី
ព្រះអង្គឥតមានអ្នកណា
ប្រៀបផ្ទឹមបានឡើយ

២៣- សិខី សព្វហិតោ សត្ថា — ព្រះសិខី
ព្រះអង្គជាគ្រូប្រៀនប្រដៅ
ធ្វើឱ្យជាប្រយោជន៍
ដល់សត្វទាំងពួង

២៤- វេស្សភូ សុខទាយកោ — ព្រះវេស្សភូ
ព្រះអង្គប្រទាននូវសេចក្តីសុខ

២៥- កកុសន្ធោ សត្ថវាហោ — ព្រះកកុសន្ធ
ព្រះអង្គនាំសត្វចេញចាកផ្លូវ
ឆ្ងាយដាច់ស្រយាល គឺកិលេស

២៦- កោនាគមនោ រណញ្ជហោ — ព្រះកោនាគមន
ព្រះអង្គបំបាក់បង់
នូវសត្រូវ គឺកិលេស

២៧- កស្សបោ សិរិសម្បន្នោ — ព្រះកស្សប
ព្រះអង្គបរិបូណ៌ដោយសិរី

២៨- ***គោតមោ សក្យបុង្គវោ*** ***ព្រះគោតម***

ព្រះអង្គប្រសើរចម្បង

ជាងពួកសក្យរាជ។

(ដកស្រង់ចេញពីសៀវភៅ ***ប្រជុំភាណវារបាលី-ប្រែ*** របស់បណ្ឌិត ***សែម សូរ*** ចាប់ទំព័រទី ១៩៣ ដល់ទំព័រទី១៩៦)។

## ៦- ព្រះពុទ្ធបដិមាជួម៉ាបច្រើនព្រះអង្គ

*ផ្អែកខាងលើ**ព្រះពុទ្ធ** ២៨ ព្រះអង្គ មានតម្កល់**ព្រះពុទ្ធបដិមា**ច្រើន**ព្រះអង្គ**។ ក្នុងសង្សារវដ្ដដែលរកខាងដើម និងខាងចុងមិនមាននេះ **ព្រះសម្មាសម្ពុទ្ធ**ដែលបានត្រាស់រួចមកហើយ មានចំនួនរាប់មិនអស់ឡើយ គឺច្រើនដូចចំនួនគ្រាប់ខ្សាច់នៅលើផែនដីទាំងមូល។*



*អ្នកមានប្រាជ្ញា កាលបើនឹករឭកឃើញដល់ការត្រាស់ដឹងរបស់**ព្រះសម្មាសម្ពុទ្ធ**ដែលធ្លាប់បានត្រាស់ដឹងឡើងក្នុងលោក រាប់មិនអស់យ៉ាងនេះ តែងកើតសេចក្ដីត្រិះរិះថា "កាល**ព្រះពុទ្ធ**ត្រាស់ដឹងនិងសម្ដែង**ព្រះធម៌** មានសត្វលោកច្រើនណាស់ដែលបានសម្រេចធម៌រួចចាកផុតទុក្ខ តើកាលនោះអាត្មាអញនៅឯណា កើតជាអ្វីហ្ន៎ ហេតុអ្វីក៏មិនបានស្ដាប់**ធម៌** និងសម្រេចគុណធម៌ដូចគេ!"។ កាលបើកើតគំនិតយ៉ាងនេះរឿយៗហើយ រមែងតាំងនូវសេចក្ដីព្យាយាមបំពេញកុសល*

ទាំងឡាយ មិនធ្វេសប្រហែស និងមិនញ៉ាំងពេលវេលាឱ្យកន្លងទៅដោយសេចក្តីប្រមាទទៀតឡើយ។

**ព្រះសម្មាសម្ពុទ្ធ** គឺជា**រតនៈ**ដ៏កម្រក្នុងលោក ព្រោះការត្រាស់ដឹងនូវ**អរិយសច្ច** ហើយអាចប្រោសសត្វលោកបាន តែងកើតចេញអំពីការសន្សំ**បារមី**អស់កាលជាអង្វែង និងលះបង់គ្រប់បែបយ៉ាង ជា**កិច្ច**ដែលកម្រមានអ្នកធ្វើបាន។

## រតនៈដ៏កម្រ ៥ យ៉ាង

ក្នុង**ព្រះត្រៃបិដក**លេខ ៤៥ ចាប់ពីទំព័រទី ៨១ **ព្រះសម្មាសម្ពុទ្ធ** សម្តែងអំពី**រតនៈ**ដ៏កម្រក្នុងលោក ៥ យ៉ាងថា៖

**បញ្ចន្នំ លិច្ឆវី រតនានំ បាតុភាវោ ទុល្លភោ លោកស្មឹ** ម្នាល**លិច្ឆវី**ទាំងឡាយ ការកើតប្រាកដនៃ**រតនៈ** ៥ ប្រការ រកបានដោយកម្រក្នុងលោក។ **កតមេសំ បញ្ចន្នំ** **រតនៈ** ៥ ដូចម្តេចខ្លះ? ដូច្នេះគឺ៖

ក- **តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បាតុភាវោ ទុល្លភោ លោកស្មឹ** ការកើតប្រាកដនៃ**ព្រះតថាគត** ជា**អរហន្តសម្មាសម្ពុទ្ធ** រកបានដោយកម្រក្នុងលោក ១

ខ- **តថាគតប្បវេទិតស្ស ធម្មវិនយស្ស ទេសិតា បុគ្គលោ ទុល្លភោ លោកស្មឹ** បុគ្គលអ្នកសម្តែងនូវ**ធម្មវិន័យ**ដែល**ព្រះតថាគត** ទ្រង់ប្រកាសហើយ រកបានដោយកម្រក្នុងលោក ១

គ- **តថាគតប្បវេទិតស្ស ធម្មវិនយស្ស វិញ្ញាតា បុគ្គលោ ទុល្លភោ លោកស្មឹ** បុគ្គលអ្នកដឹងនូវ**ធម្មវិន័យ** ដែល**ព្រះតថាគត**ប្រកាសហើយ រកបានដោយកម្រក្នុងលោក ១

ឃ- **តថាគតប្បវេទិតស្ស ធម្មវិនយស្ស ទេសិតស្ស វិញ្ញាតា ធម្មានុធម្មប្បដិបន្នោ បុគ្គលោ ទុល្លភោ លោកស្មឹ** បុគ្គលអ្នកដឹងនូវ**ធម្មវិន័យ** ដែល**ព្រះតថាគត**ប្រកាសហើយ សម្ដែងហើយៗ ប្រតិបត្តិធម៌ តាមគួរដល់**ធម៌** រកបានដោយកម្រក្នុងលោក ១

ង- **កតញ្ញូកតវេទី បុគ្គលោ ទុល្លភោ លោកស្មឹ** បុគ្គលអ្នកដឹងឧបការគុណដែលបុគ្គលដទៃធ្វើហើយ ធ្វើតបវិញ រកបានដោយកម្រក្នុងលោក ១។

**ឥមេសំ ខោ លិច្ឆវី បញ្ចន្នំ រតនានំ បាតុភាវោ ទុល្លភោ លោកស្មឹ** ម្នាល**លិច្ឆវី**ទាំងឡាយ ការកើតប្រាកដនៃ**រតនៈ**ទាំង ៥ នេះឯងរកបានដោយកម្រក្នុងលោក។

បណ្ដា**រតនៈ**ដ៏កម្រទាំង ៥ នេះ **រតនៈ**ទី ១ ពិសេសក្រៃលែង ព្រោះថា បើគ្មានការត្រាស់ដឹងឡើងរបស់**ព្រះតថាគត**ទេ **រតនៈ**បន្តបន្ទាប់ ក៏មិនប្រាកដឡើងបានដែរ។ ការសន្សំ**បារមី**របស់**ព្រះពោធិសត្វ**ជាពិសេស **និយតពោធិសត្វ** លោកមិនខ្វាចនូវការលះបង់នូវអ្វីៗគ្រប់យ៉ាងដែលលោកមានទេ គឺគ្មានអ្វីដែលលោកមិនហ៊ានលះបង់ឡើយ។

ក្នុង**ជាតកដ្ឋកថា វេស្សន្តរជាតក ទារកបព្វវណ្ណនា** បានរៀបរាប់អំពី**មហាបរិច្ចាគ** ៥ ដូច្នេះគឺៈ

១- **ធនបរិច្ចាគ** បរិច្ចាគទ្រព្យ

២- **អង្គបរិច្ចាគ** បរិច្ចាគអវយវៈ

៣- **បុត្តបរិច្ចាគ** បរិច្ចាគបុត្រ

៤- **ភរិយាបរិច្ចាគ** បរិច្ចាគភរិយា

៥- **ជីវិតបរិច្ចាគ** បរិច្ចាគជីវិត

**មហាបរិច្ចាគ**ទាំង ៥ នេះ គ្មានមួយណា ដែល**ព្រះនិយត-ពោធិសត្វ**មានព្រះទ័យខ្លាច ឬរារែកក្នុងការបរិច្ចាគឡើយ ឱ្យតែមានអ្នកត្រូវការ ហើយមិនមែនតែមួយជាតិទេ គឺច្រើនរាប់**អសង្ខេយ្យជាតិ**។ នេះជាកម្ម ដែលកម្រនឹងមានអ្នកធ្វើបាន ព្រោះហេតុនោះ ទើបការកើតឡើងនៃ**ព្រះតថាគត**ទាំងឡាយ ជាការកម្រនៅក្នុងលោក។

ពុទ្ធបរិស័ទ ដែលមកនមស្ការចំពោះ**ព្រះសម្មាសម្ពុទ្ធ** ដ៏ច្រើនអង្គនេះ មួយអន្លើដោយ**ព្រះសាវក** ៦០ អង្គ និង**អសីតិសាវក** ៨០ អង្គដែលបានរៀបរាប់មកហើយ គួរពោលនូវ**គាថា** ដូចខាងក្រោមៈ

**សម្ពុទ្ធេ អដ្ឋវីសញ្ច ទ្វាទសញ្ច សហស្សកេ**
**បញ្ចសតសហស្សានិ នមាមិ សិរសា អហំ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ**ព្រះសម្មាសម្ពុទ្ធ**ទាំងឡាយ ២៨ ព្រះអង្គផង ១ ម៉ឺន ២ ពាន់ព្រះអង្គផង ៥ សែន ព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា)។

**សម្ពុទ្ធេ បញ្ចបញ្ញាសញ្ច ចតុវីសតិសហស្សកេ**
**ទសសតសហស្សានិ នមាមិ សិរសា អហំ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ**ព្រះសម្មាសម្ពុទ្ធ**ទាំងឡាយ ៥៥ ព្រះអង្គផង ២ ម៉ឺន ៤ ពាន់ព្រះអង្គផង ១ លានព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា)។

**សម្ពុទ្ធេ នវុត្តរសតេ អដ្ឋចត្តាឡីសសហស្សកេ**
**វីសតិសតសហស្សានិ នមាមិ សិរសា អហំ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ**ព្រះសម្មាសម្ពុទ្ធ**ទាំងឡាយ ១០៩ ព្រះអង្គផង ៤ ម៉ឺន ៨ ពាន់ព្រះអង្គផង ២ លាន ព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា)។

**តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ**

ព្រះករុណា សូមក្រាបថ្វាយបង្គំនូវ**ព្រះធម៌**ផង នូវ**ព្រះសង្ឃ**ផង របស់**ព្រះសម្មាសម្ពុទ្ធ**ទាំងឡាយនោះដោយគោរព។

## ៧- រូបផ្ចាក់ផុសចេញពីជញ្ជាំងទាំង ៤ ទិស

ងាកឡើងទៅផ្នែកខាងលើបន្តិច មាន**រូបផ្ចាក់**ផុសពីជញ្ជាំង**ព្រះចេតិយ**គ្រប់ទិសទាំង៤ តំណាង**សំវេជនីយដ្ឋាន** ៤ កន្លែង គឺ កន្លែង**ប្រសូតិ** កន្លែង**ត្រាស់ដឹង** កន្លែងសម្តែង**ព្រះធម្មចក្កប្បវត្តនសូត្រ** និង កន្លែង**ទ្រង់ចូលបរិនិព្វាន**។

កាល**ព្រះបរមសាស្តា**ទៀបចូលបរិនិព្វាន **ព្រះអានន្ទ**មាន សេចក្តីខ្វល់ខ្វាយក្នុងព្រះទ័យ បានទូល**ព្រះមានព្រះភាគ** ដូចមាន សម្តែងនៅក្នុង**បិដកលេខ ១៦ មហាបរិនិព្វានសូត្រ** ចាប់ពីទំព័រ ២៩៤ ថា "បពិត្រព្រះអង្គដ៏ចម្រើន កាលពីដើម ពួកភិក្ខុនៅចាំវស្សាក្នុងទិស

ទាំងឡាយរួចហើយ តែងមកដើម្បីគាល់**ព្រះតថាគត** យើងខ្ញុំព្រះអង្គតែងបានជួបនឹងពួកភិក្ខុអ្នកចម្រើនដោយចិត្ត ធ្លាប់បានចូលទៅអង្គុយជិតគ្នា បពិត្រព្រះអង្គដ៏ចម្រើន លុះអំណឹះតតពី**ព្រះមានព្រះភាគ**ទៅ យើងខ្ញុំព្រះអង្គនឹងលែងបានជួប លែងបានចូលទៅអង្គុយជិតពួកភិក្ខុអ្នកចម្រើនដោយចិត្តហើយ”។



**ព្រះមានព្រះភាគ**ទ្រង់ត្រាស់ថា “**ម្នាលអានន្ទ សំវេជនីយដ្ឋាន** (ទីដែលគួរកើតសង្វេគ) ដែលគួរឃើញរបស់កុលបុត្តអ្នកមាន**សទ្ធា**នេះ ៤ កន្លែង។ **សំវេជនីយដ្ឋាន** ៤ កន្លែង តើដូចម្តេច? **ម្នាលអានន្ទ សំវេជនីយដ្ឋាន**ដែលគួរឃើញរបស់កុលបុត្តអ្នកមាន**សទ្ធា** ដោយរឭកឃើញថា **ព្រះតថាគត**ប្រសូតក្នុងទីនេះ ដូច្នេះ ១ **ម្នាលអានន្ទ សំវេជនីយដ្ឋាន**ដែលគួរឃើញរបស់កុលបុត្តអ្នកមាន**សទ្ធា** ដោយរឭកឃើញថា **ព្រះតថាគត**ត្រាស់ដឹងនូវ**អនុត្តរសម្មាសម្ពោធិញ្ញាណ**ក្នុងទីនេះ ដូច្នេះ ១ **ម្នាលអានន្ទ សំវេជនីយដ្ឋាន**ដែលគួរឃើញ របស់កុលបុត្ត អ្នកមាន**សទ្ធា**

ដោយរឭកឃើញថា **ព្រះតថាគត**បានសម្តែងនូវ**អនុត្តរធម្មចក្ក**ក្នុងទីនេះដូច្នេះ ១ **ម្នាលអានន្ទ សំវេជនីយដ្ឋាន**ដែលគួរឃើញ របស់កុលបុត្តអ្នកមាន**សទ្ធា** ដោយរឭកឃើញថា **ព្រះតថាគត**បរិនិព្វាន ដោយ**អនុបាទិសេសនិព្វានធាតុ**ក្នុងទីនេះ ដូច្នេះ ១។ **ម្នាលអានន្ទ** នេះឯង**សំវេជនីយដ្ឋាន**ដែលគួរឃើញ ៤ កន្លែង របស់កុលបុត្តអ្នកមាន**សទ្ធា**។ **ម្នាលអានន្ទ** ពួក**ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា** អ្នកមាន**សទ្ធា** នឹងមកដោយរឭកឃើញថា **ព្រះតថាគត**ប្រសូតក្នុងទីនេះដូច្នេះក្តី **ព្រះតថាគត**ត្រាស់ដឹងនូវ**អនុត្តរសម្មាសម្ពោធិញ្ញាណ**ក្នុងទីនេះដូច្នេះក្តី **ព្រះតថាគត**សម្តែងនូវ**អនុត្តរធម្មចក្ក**ក្នុងទីនេះដូច្នេះក្តី **ព្រះតថាគត** បរិនិព្វានដោយ**អនុបាទិសេសនិព្វានធាតុ**ក្នុងទីនេះដូច្នេះក្តី **ម្នាលអានន្ទ** ពួកជនណាមួយ នឹងបានដើរមកកាន់ទីចារិកនៃ**ចេតិយ** ក៏មានចិត្តជ្រះថ្លា ប្រសិនបើធ្វើមរណកាលបែកធ្លាយរាងកាយទៅ ពួកជនទាំងអស់នោះ ខាងមុខអំពីសេចក្តីស្លាប់ នឹងចូលទៅកាន់លោក គឺ**មនុស្សសុគតិ** និង**ឋានសួគ៌**។

**សំវេជនីយដ្ឋាន**ទាំង ៤ មិនមែនគ្រប់គ្នា សុទ្ធតែបានទៅគោរពបូជានោះទេ ព្រោះថា អ្វីៗគ្រប់យ៉ាងតែងកើតពី**បច្ច័យ** អ្នកខ្លះនៅជិត ប៉ុន្តែខ្វះ**សទ្ធា** អ្នកខ្លះមាន**សទ្ធា** ប៉ុន្តែខ្វះមធ្យោបាយក្នុងការធ្វើដំណើរ អ្នកខ្លះមានទាំង**សទ្ធា**និង**លទ្ធភាព** ប៉ុន្តែខ្វះ**ឱកាស**។ ដូច្នេះទើបក្នុងការកសាងព្រះ**បទុមចេតិយ**នេះ ខ្ញុំបានរៀបចំរូបចម្លាក់ផុសទាំង ៤ ផ្ទាំង តំណាងឱ្យ**សំវេជនីយដ្ឋាន**ទាំង ៤ កន្លែងតែម្តង។

ដូច្នេះអ្នកដែលចូលមកថ្វាយបង្គំនូវ**ព្រះបទុមចេតិយ** កុំភ្លេចបង្អោនចិត្តទៅកាន់ទី**សំវេជនីយដ្ឋាន**ទាំង ៤ កន្លែងផង។

## ៨- កន្លែងតម្កល់ព្រះសារីរិកធាតុ

ផ្នែកខាងលើនៃ**សំវេជនីយដ្ឋាន**ទាំង ៤ គឺជាកន្លែងតម្កល់ **ព្រះបរមសារីរិកធាតុ** នៃ**ព្រះសម្មាសម្ពុទ្ធសមណគោតមបរមគ្រូជាម្ចាស់** និង**រតនវត្ថុ**ផ្សេងៗ ជា**ពុទ្ធបូជា**។



## ប្រវត្តិសង្ខេបនៃព្រះសារីរិកធាតុ

ក្រោយពេល**ព្រះសម្មាសម្ពុទ្ធ**ទ្រង់ចូលកាន់**បរិនិព្វាន** ៧ ថ្ងៃ ការបូជា**ព្រះសរីរៈ**របស់ព្រះអង្គក៏បានធ្វើឡើង។ ពួកស្តេចពីនគរផ្សេងៗ បានបញ្ជូនទូតរបស់ខ្លួនទៅ ដើម្បីទាមទារ**ព្រះបរមសារីរិកធាតុ** យកទៅតម្កល់ទុកក្នុង**ព្រះស្តូប**ដែលគ្រោងសាងឡើងភ្លាមៗ ក្នុងនគររៀងៗខ្លួន។ ការដណ្តើមទាមទារជាកម្មសិទ្ធិ រហូតក្លាយជាជម្លោះពាក្យសម្តីក៏បានកើតឡើង ប៉ុន្តែជាភ័ព្វល្អ ក្នុងទីនោះមានព្រាហ្មណ៍ម្នាក់ ឈ្មោះថា

***ទោណព្រាហ្មណ៍*** *ជាព្រាហ្មណ៍ព្រឹទ្ធាចារ្យ បាននិយាយទៅកាន់* ***គណៈទូត*** *(បិដកលេខ ១៦ ចាប់ពីទំព័រទី ៣៤៦) ទាំងនោះ ដូច្នេះថា៖*

*លោកទាំងឡាយដ៏ចម្រើន សូមស្តាប់ពាក្យរបស់ខ្ញុំមួយម៉ាត់សិន* ***ព្រះពុទ្ធ****ជាម្ចាស់នៃយើង ព្រះអង្គជា****ខន្តិវាទ*** *(អ្នកពោលសរសើរគុណនៃ****ខន្តី****) មែនពិត ការប្រហារគ្នា (ច្បាំងគ្នា) ព្រោះតែចំណែកនៃ****ព្រះសរីរធាតុ*** *របស់****ឧត្តមបុគ្គល****នេះ មិនប្រពៃឡើយ។ បពិត្រលោកទាំងឡាយដ៏ចម្រើន យើងទាំងអស់គ្នា (គួរតែ) ស្រុះស្រួលគ្នា ព្រមព្រៀងគ្នា រីករាយរកគ្នា ចែក****ព្រះសរីរធាតុ****ឱ្យជា ៨ ចំណែក* ***ព្រះស្តូប****ទាំងឡាយ សូមផ្សាយទៅក្នុងទិសទាំងឡាយចុះ ពួកជនច្រើន គង់ជ្រះថ្លាចំពោះ****ព្រះសម្ពុទ្ធ****ដ៏មានចក្ខុ មិនលែង។*

*ពួកក្សត្រ និងព្រាហ្មណ៍ទាំងនោះ ទទួលពាក្យថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរចែក****ព្រះសរីរធាតុ*** *នៃ****ព្រះមានព្រះភាគ*** *ឱ្យជា ៨ ចំណែកស្មើគ្នាចុះ។* ***ទោណព្រាហ្មណ៍*** *ក៏ទទួលពាក្យរបស់****គណៈទូត*** *ទាំងនោះ ដោយពាក្យថា អើអ្នកដ៏ចម្រើន អើអ្នកដ៏ចម្រើន ហើយក៏ចែក* ***ព្រះសរីរធាតុ*** *នៃ****ព្រះមានព្រះភាគ****ឱ្យជា ៨ ចំណែកស្មើភាគគ្នា ហើយនិយាយនឹងពួក****គណៈទូត****ទាំងនោះ ដូច្នេះថា លោកទាំងឡាយដ៏ចម្រើន សូមលោកទាំងឡាយដ៏ចម្រើន ឱ្យ****តុម្ព*** *(ជាឈ្មោះរង្វាល់ម្យ៉ាងនៅ****ប្រទេសឥណ្ឌា****ក្នុងកាលនោះ) នេះដល់ខ្ញុំចុះ ខ្ញុំនឹងធ្វើ****ព្រះស្តូប****ផង ការបូជាផងចំពោះ****តុម្ព****។ ពួកក្សត្រនិងព្រាហ្មណ៍ទាំងនោះ ក៏បានឱ្យ****តុម្ព*** *ដល់ទោណព្រាហ្មណ៍។*

## ការបែងចែកព្រះសារីរិកធាតុទៅកាន់ទិសផ្សេងៗ

*ក្នុងបិដកដដែល ទំព័រទី ៣៤៩ សម្តែងថា **ព្រះសរីរធាតុ**របស់**ព្រះសម្ពុទ្ធ**ដ៏មានចក្ខុ មានចំនួន ៨ **ទោណៈ ព្រះសរីរធាតុ ៧ ទោណៈ** ជនទាំងឡាយធ្វើសក្ការបូជាក្នុង**ជម្ពូទ្វីប** **ព្រះសរីរធាតុ**របស់**ព្រះសម្ពុទ្ធ** ជាបុរសដ៏ប្រសើរខ្ពង់ខ្ពស់ ១ **ទោណៈ**ទៀត ពួកនាគរាជធ្វើសក្ការបូជា ក្នុង**រាមគ្រាម**ៗ **ព្រះទាឋា** (ចង្កូម) ១ ពួកទេវតានាំយកទៅបូជា **ព្រះទាឋា** ១ ទៀត ពួកជនធ្វើសក្ការបូជាក្នុង**គន្ធារបុរី ព្រះទាឋា** ១ ទៀត ពួកជនធ្វើសក្ការបូជាក្នុងដែនរបស់**ស្តេចកាលិង្គ ព្រះទាឋា** ១ ទៀត ពួកនាគរាជនាំយកទៅធ្វើសក្ការបូជាៗ ហេតុតែតេជះនៃ**ព្រះសរីរធាតុ**របស់**ព្រះមានព្រះភាគ**នោះឯង មហាប្រឹថពីនេះ ក៏បានប្រដាប់ដោយគ្រឿងបូជាវិសេស ឯ**ព្រះសរីរធាតុ**របស់**ព្រះសម្ពុទ្ធ**មានចក្ខុនេះ គឺពួកសត្វដែលធ្លាប់ធ្វើនូវគ្រឿងសក្ការៈដ៏លើសលុបទាំងឡាយ បានធ្វើសក្ការៈដោយល្អហើយយ៉ាងនេះៗ ស្តេចទេវតា ស្តេចនាគ និងស្តេចមនុស្ស ទាំងពួកមនុស្សអ្នកប្រសើរ ក៏បានធ្វើការបូជា**ព្រះអង្គ**ហើយដូច្នេះដែរ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរផ្គងអញ្ជលីឡើង ថ្វាយបង្គំ**ព្រះពុទ្ធ**ជាម្ចាស់នោះចុះ ព្រោះថា **ព្រះពុទ្ធ**ជាម្ចាស់ទាំងឡាយជាបុគ្គលរកបានក្រ ដោយរយនៃ**កប្ប**ទាំងឡាយៗ **ព្រះទន្ត** ទាំង ៤០ គត់ក្តី **ព្រះកេសា**ក្តី **ព្រះលោមា**ក្តី ទាំងអស់ ពួកទេវតាដែលនៅក្នុងចក្រវាលតៗគ្នា នាំយកទៅមួយៗម្នាក់ៗ*

កន្លែងតម្កល់**ព្រះសារីរិកធាតុ** មានខ្លោងទ្វារបែរទៅកាន់ទិសទាំង ៤ ដែលតំណាងឱ្យ**ព្រហ្មវិហារធម៌** ឬហៅថា**អប្បមាណធម៌** ដ៏មហាធំធេងរកប្រមាណមិនបានរបស់**ព្រះពុទ្ធបរមគ្រូ** ដែលព្រះទ័យរបស់ព្រះអង្គ គឺជាម្ហូបដ៏ត្រជាក់ផ្សាយចេញតាមរយៈការសម្ដែងពន្យល់នូវ**ព្រះធម៌ ព្រះវិន័យ** ប្រោសសត្វលោកមិនដែលខ្វាចនឿយហត់។ **ព្រហ្មវិហារធម៌** ឬ**អប្បមាណធម៌**ទាំង ៤ នោះគឺ **មេត្តា ករុណា មុទិតា និងឧបេក្ខា**។ ព្រោះតែ**ព្រះអង្គ**មាននូវ**ព្រហ្មវិហារធម៌**ចំពោះសត្វលោករកប្រមាណមិនបាននេះឯង ទើបក្នុងរយៈពេល ៤៥ ព្រះវស្សា ទ្រង់បំពេញនូវ**ព្រះពុទ្ធកិច្ច**ជាប្រចាំគឺ៖

១- **ពេលព្រឹក** ទ្រង់បិណ្ឌបាត្រ

២- **ពេលរសៀល** ទ្រង់ទេសនាប្រោសបរិស័ទ

៣- **ពេលព្រលប់** ទ្រង់ឱ្យឱវាទដល់ភិក្ខុសង្ឃ

៤- **ពេលអធ្រាត** ទ្រង់ដោះស្រាយប្រស្នាពួកទេវតា

៥- **ពេលទៀបភ្លឺ** ទ្រង់ប្រមើលមើលឧបនិស្ស័យសត្វ។

**ពុទ្ធកិច្ច**ជាប្រចាំថ្ងៃទាំង ៥ ខាងលើ បើព្រះអង្គមិនមានព្រះទ័យពោរពេញដោយ**មេត្តា ករុណា** ពិតជាធ្វើមិនបានទេ ហើយការងារនេះទៀតសោត មានតែ**ព្រះពុទ្ធ**ប៉ុណ្ណោះដែលអាចធ្វើបាន គ្មានសាវកអង្គណាមួយគ្រាប់បានឡើយ។

ម្យ៉ាងទៀត **ខ្លោងទ្វារ**ទាំង ៤ នេះ ជាការប្រកាសប្រាប់ថា **ព្រះបទុមចេតិយ** តែងស្វាគមន៍ការនិមន្ត និងអញ្ជើញមកនៃ**ពុទ្ធបរិស័ទ** អំពីទិសទាំង ៤។

## ធាតុចេតិយនមស្ការគាថា

អ្នកដែលមកនមស្ការចំពោះ**ព្រះសារីរិកធាតុ** ដែលតម្កល់ក្នុង**ព្រះបទុមចេតិយ**នេះ គួរតែសូត្រ ឬពោលនូវ**ព្រះគាថា**ទាំងឡាយ ដែលខ្ញុំបានដកស្រង់ចេញពីសៀវភៅ **ប្រជុំភាណវារបាលី-ប្រែ** របស់បណ្ឌិត **សែម សូរ** ដូចតទៅៈ

**មហាគោតមសម្ពុទ្ធោ កុសិនារាយ និព្វុតោ**
**ធាតុវិត្ថារកំ កត្វា តេសុ តេសុ វិសេសតោ**

**ព្រះគោតមបរមសម្ពុទ្ធ**ដ៏ប្រសើរ ព្រះអង្គ**បរិនិព្វាន**ហើយ ជិតក្រុង**កុសិនារា** ធ្វើនូវកិរិយាផ្សាយនូវ**ព្រះសារីរិកធាតុ** ក្នុងទីទាំងឡាយនោះៗ ដោយផ្សេងៗគ្នា។

**ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច សត្តមា**
**អសម្ភិន្នា វ តា សត្ត សេសា ភិន្នា វ ធាតុយោ**

**ព្រះសារីរិកធាតុ**ទាំងឡាយនោះ ដែលមិនបែកចេញមាន ៧ អង្គ គឺ **ព្រះឧណ្ហីសធាតុ** ១ **ព្រះទាឋធាតុ** ៤ **ព្រះអក្ខកធាតុ** ២ **ព្រះសារីរិកធាតុ**ដ៏សេសក្រៅពីនោះសុទ្ធតែបែកចេញ ( ជាចំណែកតូចៗ)។

**មហន្តា បញ្ច នាឡី ច មជ្ឈិមា ច ឆ នាឡិយោ**
**ខុទ្ទកា បញ្ច នាឡី ច សម្ភិន្នា តិវិធា មតា**

**ព្រះបរមធាតុ**ទាំងឡាយដែលបែកចេញ លោកពោលថាមាន ៣ យ៉ាង គឺ**ព្រះធាតុ**ខ្នាតធំវាល់បានចំនួន ៥ **នាឡិ** **ព្រះធាតុ**ខ្នាតកណ្តាលវាល់បានចំនួន ៦ **នាឡិ** **ព្រះធាតុ**ខ្នាតតូចវាល់បានចំនួន ៥ **នាឡិ**។

មហន្តា ភិន្នមុគ្គា ច មជ្ឈិមា ភិន្នតណ្ឌុលា
ខុទ្ទកា សាសបមត្តា ឯវំ ធាតុប្បមាណិកា

**ព្រះបរមធាតុ**ទាំងឡាយ មានប្រមាណយ៉ាងនេះ គឺ**ព្រះធាតុ**ខ្នាតធំ មានទំហំប៉ុនកំណាត់គ្រាប់សណ្តែកបាយ **ព្រះធាតុ**ខ្នាតកណ្តាល មានទំហំប៉ុនកំណាត់គ្រាប់អង្ករ **ព្រះធាតុ**ខ្នាតតូច មានទំហំប៉ុនគ្រាប់ស្ពៃ។

មហន្តា សុវណ្ណវណ្ណា មជ្ឈិមា ផលិកប្បភា
ខុទ្ទកា ពកុលវណ្ណា តាបិ វន្ទាមិ ធាតុយោ

**ព្រះបរមធាតុ**ទាំងឡាយ (មានពណ៌ផ្សេងគ្នាយ៉ាងនេះគឺ) **ព្រះធាតុ**ខ្នាតធំ មានពណ៌ដូចមាស **ព្រះធាតុ**ខ្នាតកណ្តាល មានពណ៌ដូចកែវផលិក **ព្រះធាតុ**ខ្នាតតូច មានពណ៌ដូចផ្កាថ្កុល ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវ**ព្រះបរមធាតុ**ទាំងឡាយនោះ។

ឯកោ ថូបោ រាជគហេ ឯកោ វេសាលិយា អហុ
ឯកោ កបិលវត្ថុស្មឹ ឯកោ ច អលកប្បកេ
ឯកោ ច រាមគាមស្មឹ ឯកោ ច វេដ្ឋទីបកេ
ឯកោ បាវេយ្យកេ មល្លេ ឯកោ ច កុសិនារកេ

**ព្រះសថូប** ១ ប្រតិស្ឋាននៅក្នុងក្រុង**រាជគ្រឹះ** **ព្រះសថូប** ១ ប្រតិស្ឋាននៅក្នុងក្រុង**វេសាលី** **ព្រះសថូប** ១ ប្រតិស្ឋាននៅក្នុងក្រុង**កបិលភ័ស្តុ** **ព្រះសថូប** ១ ប្រតិស្ឋាននៅក្នុងក្រុង**អលកប្បកៈ** **ព្រះសថូប** ១ ប្រតិស្ឋាននៅក្នុង**រាមគ្រាម** **ព្រះសថូប** ១ ប្រតិស្ឋាននៅក្នុង

ក្រុង**វេដ្ឋទីបកៈ** **ព្រះសថូប** ១ ប្រតិស្ឋាននៅក្នុងក្រុង**បាវេយ្យកៈ** ក្នុង**មល្លរដ្ឋជនបទ** **ព្រះសថូប** ១ ប្រតិស្ឋាននៅក្នុងក្រុង**កុសិនារា**។

**ឯតេ សារីរិកា ថូបា ជម្ពុទីបេ បតិដ្ឋិតា**

**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

**ព្រះសថូប** (ទាំង៨) នុ៎ះ ជា**ព្រះសថូប**បញ្ចុះ**ព្រះបរមសារីរិកធាតុ** ប្រតិស្ឋាននៅក្នុង**ជម្ពូទ្វីប** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ**ព្រះបរមធាតុ**ទាំងឡាយ (ក្នុង**ព្រះសថូប**ទាំង ៨ នោះ) ដែលទេវតានិងមនុស្សទាំងឡាយតែងបូជា។

**ឯកា ទាឋា តិទសបុរេ ឯកា នាគបុរេ អហុ**

**ឯកា គន្ធារវិសយេ ឯកា សីហឡទីបកេ**

**ព្រះទាឋធាតុ**អង្គ ១ ប្រតិស្ឋាននៅក្នុងស្ថាន**ត្រ័យត្រិង្ស** **ព្រះទាឋធាតុអង្គ** ១ ប្រតិស្ឋាននៅក្នុង**ពិភពនាគ** **ព្រះទាឋធាតុ**អង្គ ១ ប្រតិស្ឋាននៅក្នុង**គន្ធាររដ្ឋ** **ព្រះទាឋធាតុ**អង្គ ១ ប្រតិស្ឋាននៅក្នុង**សីហឡទ្វីប**។

**ឥមា ចតូសុ ឋានេសុ សត្ត ទាឋា បតិដ្ឋិតា**

**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

**ព្រះទាឋធាតុ**ទាំងឡាយនេះ របស់**ព្រះបរមសាស្តា** ប្រតិស្ឋាននៅក្នុងទីទាំងឡាយ ៤ កន្លែង ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ**ព្រះធាតុ**ទាំងឡាយ ដែលទេវតា និងមនុស្សទាំងឡាយតែងបូជា។

**ឧទ្ធំ ទក្ខិណទាឋា ច តាវត្តឹសេ បតិដ្ឋិតា**

**អធោ ទក្ខិណទាឋា ច សីហឡទីបេ បតិដ្ឋិតា**

វាមទាឋា ច ឧទ្ធម្បិ គន្ធាររដ្ឋេ បតិដ្ឋិតា
វាមទាឋា ច អធោបិ នាគលោកេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ

ព្រះទាឋធាតុស្តាំខាងលើ ប្រតិស្ឋាននៅក្នុង**ស្ថានតាវត្តិង្ស** **ព្រះទាឋធាតុ**ស្តាំខាងក្រោម ប្រតិស្ឋាននៅក្នុង**សីហឡទ្វីប** **ព្រះទាឋធាតុ**ឆ្វេងខាងលើ ប្រតិស្ឋាននៅក្នុង**ដែនគន្ធារ** **ព្រះទាឋធាតុ**ឆ្វេងខាងក្រោម ប្រតិស្ឋាននៅក្នុង**ពិភពនាគ** ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ**ព្រះធាតុ**ទាំងឡាយ ដែលទេវតានិងមនុស្សទាំងឡាយតែងបូជា។

ព្រហ្មលោកេ ទុស្សធាតុ- វាមអក្ខកធាតុយោ
សព្វេ ព្រហ្មាភិបូជេន្តិ ថូបំ ទ្វាទសយោជនំ

**ព្រះទុស្សធាតុ** និង**ព្រះអក្ខកធាតុ**ខាងឆ្វេង ប្រតិស្ឋាននៅក្នុង**ព្រហ្មលោក** ព្រហ្មទាំងឡាយទាំងអស់គ្នា តែងបូជានូវ**ព្រះសថូប**កម្ពស់ ១២ យោជន៍ (ដែលបញ្ចុះនូវ**ធាតុ**ទាំងនោះ)។

តាវត្តឹសម្ហិ ទេវានំ ចុឡាមណិម្ហិ កេសកំ
សព្វេ ទេវាភិបូជេន្តិ បសន្នា ពុទ្ធសាសនេ
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ

ទេវតាទាំងឡាយទាំងពួង ដែលជាអ្នកជ្រះថ្លាក្នុង**ព្រះពុទ្ធសាសនា** តែងបូជានូវ**ព្រះកេសធាតុ**ដែលប្រតិស្ឋាននៅក្នុង**ចុឡាមណីចេតិយ**របស់ទេវតាទាំងឡាយក្នុង**ស្ថានត្រ័យត្រិង្ស** ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវ**ព្រះធាតុ**ទាំងឡាយ ដែលទេវតា និងមនុស្សទាំងឡាយតែងបូជា។

ចត្តាឡីស សមាទន្តា    កេសា លោមា នខាបិ ច
ទេវា ហរន្តិ ឯកេកំ    ចក្កវាឡបរម្បរា
បូជិតា នរទេវេហិ    អហំ វន្ទាមិ ធាតុយោ

**ព្រះទន្តធាតុ**ទាំងឡាយ ៤០ គត់ផង **ព្រះកេសធាតុ**ទាំងឡាយផង **ព្រះលោមធាតុ**ទាំងឡាយផង **ព្រះនខធាតុ**ទាំងឡាយផង ទេវតាទាំងឡាយ នាំទៅនូវ**ព្រះធាតុ** ១ អង្គៗ កាន់**ចក្រវាល**ដទៃនិងដទៃ គឺ**ព្រះធាតុ** ១ អង្គៗ ក្នុង**ចក្រវាល**មួយៗ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ**ព្រះធាតុ**ទាំងឡាយ ដែលទេវតា និងមនុស្សទាំងឡាយតែងបូជា។

អដ្ឋារសេ ទ្វេ វស្សសតេ    ធម្មាសោកោ តទា អហុ
ចតុរាសីតិសហស្សា    ចេតិយា ច ការាបិតា
បូជិតា នរទេវេហិ    អហំ វន្ទាមិ ធាតុយោ

នាកាល**ព្រះពុទ្ធសករាជ**បាន ២១៨ ឆ្នាំ មាន**ព្រះមហាក្សត្រ** ១ អង្គ ទ្រង់**ព្រះនាមធម្មាសោក** ក្នុងកាលនោះ**ព្រះអង្គ**បានកសាង**ព្រះចេតិយ**ចំនួន ៨ ម៉ឺន ៤ ពាន់ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវ**ព្រះធាតុ**ទាំងឡាយ (ក្នុង**ព្រះចេតិយ**ទាំងនោះ) ដែលទេវតា និងមនុស្សទាំងឡាយតែងបូជា។

## ៩- ស្រទាប់ផ្កាឈូក ៩ ថ្នាក់

*ងាកទៅខាងលើបន្តិច យើងនឹងឃើញ**ស្រទាប់ផ្កាឈូក** ៩ ថ្នាក់ ដែលតំណាងឱ្យឋានដ៏បរិសុទ្ធ គឺ**សុទ្ធាវាសភូមិ** ៥ ជាន់។*



## សុទ្ធាវាសភូមិ ៥

***សុទ្ធាវាសព្រហ្ម** ស្ថិតនៅក្នុង**សុទ្ធាវាសភូមិ** គឺភូមិជាទីនៅនៃ**ព្រះអនាគាមី** និង**ព្រះអរហន្ត**ប៉ុណ្ណោះ មាន ៥ ជាន់គឺះ*

*ក- **អវិហា*** *មានន័យថា មិនលះ**ឋាន**របស់ខ្លួន ដោយកាលបន្តិចបន្តួច ឬថា មិនសាបសូន្យចាកសម្បត្តិរបស់ខ្លួន មានអាយុ ១ ០០០ មហាកប្ប*

*ខ- **អតប្បា*** *មានន័យថា មិនមានការភ័យខ្លាចអ្វីៗ ទាំងអស់ មានអាយុ ២ ០០០ មហាកប្ប*

*គ- **សុទស្សា*** *មានន័យថា ប្រាកដបានងាយ ព្រោះព្រហ្មទាំង*

នោះ មានរូបល្អក្រៃលែង មានអាយុ ៤ ០០០ មហាកប្ប

ឃ- **សុទស្សី** មានន័យថា ឃើញបានដោយងាយ ព្រោះព្រហ្ម ទាំងនេះ មានការឃើញដ៏បរិសុទ្ធ មានអាយុ ៨ ០០០ មហាកប្ប

ង- **អកនិដ្ឋា** មានន័យថា ជាព្រហ្មអ្នកមានសម្បត្តិយ៉ាងឧក្រិដ្ឋ គឺមិនមានការថយចុះ មានអាយុ ១៦ ០០០ មហាកប្ប។

**ព្រះអរិយបុគ្គល**ដ៏ច្រើន ដែលបានសម្រេចជាព្រះ**អនាគាមី** កាលនៅជាមនុស្សឬជាទេវតា លុះចុតិទៅ តែងបដិសន្ធិក្នុង**សុទ្ធាវាសភូមិ** តាមលំដាប់ ហើយនឹង**បរិនិព្វាន**ក្នុង**អកនិដ្ឋភូមិ**ជាទីបំផុត។ ដូច្នេះ ការថ្វាយបង្គំនូវស្រទាប់ផ្កាឈូកប្រាំថ្នាក់នេះ គឺផ្តោតឧទ្ទិសចំពោះ**ព្រះអរិយបុគ្គល**ថ្នាក់ខ្ពស់ ដែលជា**ព្រះអនាគាមី** និង**ព្រះអរហន្ត** ដែលកំពុងធរមាននៅដល់សព្វថ្ងៃ។

ប្ញីដ្បិតថា **ស្ថានសួគ៌**មិនមែនជាទីផុតទុក្ខ ប៉ុន្តែយ៉ាងហោចក៏មិនសោយទុក្ខដូចនៅក្នុង**អបាយភូមិ** ម្យ៉ាងទៀតជាស្ថានដែលនៅសម្បូរដោយ**ព្រះអរិយបុគ្គល**នៅឡើយ បើបច្ច័យគ្រប់ឱ្យបដិសន្ធិនៅទីនោះ ការសន្សំនូវ**សម្មាទិដ្ឋិ**ព្រោះការស្តាប់ធម៌រឿយៗ រាល់ថ្ងៃ ក៏នឹងអាចបានស្តាប់**ធម៌ព្រះអរិយៈ**បន្តទៀតក្នុងស្ថាននោះៗ ហើយបើឧបនិស្ស័យគ្រប់ ក៏នឹងអាចសម្រេច**មគ្គផល**ក្នុងស្ថាននោះៗ ចុងក្រោយនឹង**បរិនិព្វាន** ក្នុង**អកនិដ្ឋភព**តែម្តង។

## ១០- កំពូលព្រះបទុមចេតិយ

*នៅត្រង់កំពូល**ព្រះបទុមចេតិយ** ជា**កណ្ដឹងមូល** សាងអំពីស្ពាន់ តំណាងឱ្យ**ព្រះនិព្វាន** ដែលជា**ឯកន្តបរមសុខ**។ បណ្ដា**ធម៌ទាំងឡាយ** **លោកុត្តរធម៌**ជាធម៌ដ៏ប្រសើរ ហើយបណ្ដា**លោកុត្តរធម៌**ទាំង ៩ **ព្រះនិព្វាន** ប្រសើរជាងគេបំផុត ព្រោះជា**អសង្ខតធម៌** ជា**ធម៌**មិនកើតរលត់ ជា**ធម៌**គ្មាន**បច្ច័យ**ប្រជុំតាក់តែង។*



*ក្នុងលោកនេះ គ្មានសេចក្ដីសុខពិតទេ បើទោះជាមានសុខខ្លះ ក៏មានត្រឹមតែ**សុខវេទនា**ប៉ុណ្ណោះ ដែលស្ថិតក្រោមច្បាប់នៃ**ត្រៃលក្ខណ៍** តែងមានសេចក្ដីប្រែប្រួលជាធម្មតា។ អ្នកមានប្រាជ្ញា បានឃើញនូវសភាពមិនទៀងនៃ**សង្ខារធម៌**គ្រប់យ៉ាងដូច្នេះហើយ ទើបលោកមានមុខឆ្ពោះទៅកាន់**ព្រះនិព្វាន** តាមរយៈ**អរិយមគ្គ**មានអង្គ ៨ ជាមាគ៌ាតែមួយគត់ ដែលអាចរំលត់ទុក្ខគ្រប់យ៉ាង។*

## លក្ខណៈរបស់ព្រះនិព្វាន

| | |
|---|---|
| ១- **អសេសវិរាគនិរោធោ** | ជាធម៌ដែលរំលត់ទុក្ខ ដោយប្រាសចាករាគៈមិនមានសេសសល់។ |
| ២- **អសេសភវនិរោធោ** | ជាធម៌ដែលរំលត់ភពមិនមានសេសសល់។ |
| ៣- **ចាគោ** | ជាធម៌ដែលលះចោលតណ្ហាទាំងពួង។ |
| ៤- **បដិនិស្សគ្គោ** | ជាធម៌ដែលរួចផុតចាកភព។ |
| ៥- **មុត្តិ** | ជាធម៌ដែលរួចផុតចាកកិលេស។ |
| ៦- **អនាលយោ** | ជាធម៌ដែលមិនមានសេចក្តីអាល័យ។ |
| ៧- **រាគក្ខយោ** | ជាធម៌ដែលអស់ទៅនៃរាគៈ។ |
| ៨- **ទោសក្ខយោ** | ជាធម៌ដែលអស់ទៅនៃទោសៈ។ |
| ៩. **មោហក្ខយោ** | ជាធម៌ដែលអស់ទៅនៃមោហៈ។ |
| ១០- **តណ្ហក្ខយោ** | ជាធម៌ដែលអស់ទៅនៃតណ្ហា។ |
| ១១- **អនុប្បាទោ** | ជាធម៌ដែលរំលត់ខន្ធទាំង ៥។ |
| ១២. **អបវត្តំ** | ជាធម៌ដែលរំលត់នាមរូប។ |
| ១៣- **អនិមិត្តំ** | ជាធម៌ដែលប្រាសចាកសង្ខារនិមិត្ត។ |
| ១៤- **អប្បណិហិតំ** | ជាធម៌ដែលប្រាសចាកសេចក្តីត្រូវការ។ |
| ១៥- **សុញ្ញតំ** | ជាធម៌ដែលសូន្យចាកទុក្ខបានពិតមែន។ |
| ១៦- **អប្បដិសន្ធិ** | ជាធម៌ដែលមិនមានការកើតបន្ត។ |
| ១៧- **អនុប្បត្តិ** | ជាធម៌ដែលមិនមានទីទៅ។ |
| ១៨- **អនាយូហនំ** | ជាធម៌ដែលមិនមានការព្យាយាម។ |

១៩- **អជាតំ** ជាធម៌ដែលមិនមានការកើត។

២០- **អជរំ** ជាធម៌ដែលមិនមានការចាស់។

២១- **អព្យាធិ** ជាធម៌ដែលមិនមានការឈឺចាប់។

២២- **អគតិ** ជាធម៌ដែលមិនមានគតិ។

២៣- **អមតំ** ជាធម៌ដែលមិនមានការស្លាប់។

២៤- **អសោកំ** ជាធម៌ដែលមិនមានសេចក្ដីសោក។

២៥- **អបរិទេវំ** ជាធម៌ដែលមិនមានសេចក្ដីខ្សឹកខ្សួល។

២៦- **អនុបាយាសោ** ជាធម៌ដែលមិនមានសេចក្ដីចង្អៀតចង្អល់ចិត្ត។

២៧- **អសង្កិលិដ្ឋំ** ជាធម៌ដែលមិនមានសេចក្ដីសៅហ្មង។

២៨- **អសង្ខតំ** ជាធម៌ដែលមិនមានបច្ច័យតាក់តែង។

២៩- **និវានំ** ជាធម៌ដែលផុតចាកគ្រឿងដោតក្រង។

៣០- **សន្តិ** ជាធម៌ដែលស្ងប់ចាកទុក្ខទាំងពួង។

លម្អរបស់**ព្រះនិព្វាន**ដោយសង្ខេបទាំងនេះ អាស្រ័យ**គុណធម៌**របស់លោកអ្នកដែលបានសម្រេចនូវ**និព្វាន**ហើយ ទើបដឹងច្បាស់ថា**ព្រះនិព្វាន**មានពិតប្រាកដមែន។

មុនក្លាយជា**ព្រះអរិយបុគ្គល** លោកទាំងឡាយនោះក៏ជា**បុថុជ្ជន**ដូចយើងគ្រប់គ្នាដែរ ដូច្នេះយើងគ្រប់គ្នាក៏នឹងមានឱកាសក្លាយជា**អរិយ-បុគ្គល**នៅថ្ងៃណាមួយ ព្រោះអាស្រ័យ**បុណ្យកុសល**ដែលយើងកំពុងតែបំពេញរាល់ថ្ងៃនេះឯង។

## មហាសុបិន ៥ ប្រការ

*ពេលពុទ្ធបរិស័ទចូលទៅក្នុង**ព្រះបទុមចេតិយ**ក្លាម ប្រាកដជាឃើញរូបគំនូរមួយចំនួន តាមជញ្ជាំងពីខាងក្នុង ដែលគំនូរទាំងនេះមិនសូវប្រទះឃើញពីមុនមកនោះទេ។ សូមអាននូវសំណេរខាងក្រោម ដើម្បីយល់ដឹងនូវអត្ថន័យនៃគំនូរនីមួយៗ។*

*នៅក្នុង**បច្ចុសសម័យ** គឺពេលទៀបភ្លឺ ឈានចូលថ្ងៃ ១៥កើត ខែពិសាខ ឆ្នាំរកា មុនពុទ្ធសករាជ ៤៥ ព្រះវស្សា **ព្រះបរមពោធិសត្វ**ទ្រង់មាន**សុបិន**ដ៏អស្ចារ្យ ដែលជាសុបិនចុងក្រោយបង្អស់របស់ព្រះអង្គ ក្នុងសង្សារវដ្ត ហៅថា "**មហាសុបិន**"។ ក្រោយពេល**ព្រះអង្គ**ទ្រង់ឃើញនូវ**មហាសុបិន**ទាំងនោះហើយ **ព្រះអង្គ**ក៏តើនចាក**ទីសយនា** ទ្រង់សន្និដ្ឋានក្នុងព្រះទ័យថា "**អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធ**" រួច**ព្រះអង្គ**បានព្យាករណ៍នូវ**មហាសុបិន**ទាំងនោះ ដោយ**ព្រះអង្គ**ឯងផ្ទាល់តែម្តង។ **មហាសុបិន**ទាំងនោះ មាន ៥ គឺ៖*

### មហាសុបិនទី ១

- ***ព្រះអង្គ**ឃើញមហាប្រឹថពីជា**ទីសយនា**ក្រឡាបន្ទំ*
- ***ភ្នំហិមវន្ត**ជាខ្នើយរង**ព្រះសិរ***
- ***ព្រះហស្ត**ខាងឆ្វេងសណ្តូកចុះក្នុងមហាសមុទ្ទ ខាងទិសបូព៌*
  ***ព្រះហស្ត**ខាងស្តាំសណ្តូកចុះក្នុងមហាសមុទ្ទ ខាងទិសបស្ចិម*
  ***ព្រះបាទ**ទាំងពីរសណ្តូកចុះក្នុងមហាសមុទ្ទ ខាងទិសទក្សិណ*
- *ទ្រង់ផ្ទំ**ផ្ងារ***
- *ទ្រង់ផ្ទំដោយបើក**ព្រះនេត្រ***

- ទ្រង់ឃើញពន្លឺដរាបដល់**ភវគ្គព្រហ្ម** (ព្រហ្មដ៏ខ្ពស់បំផុត)។



❖ ទ្រង់ព្យាករណ៍ថា៖

- **ការផ្ទំលើផែនដី** ជា**បុព្វនិមិត្ត**នៃកិរិយាបាននូវ**អនុត្តរសម្មាសម្ពោធិញ្ញាណ**។
- **ភ្នំហិមវន្តជាខ្នើយរង់ព្រះសិរ** ជា**បុព្វនិមិត្ត**នៃកិរិយាបាននូវខ្នើយ គឺ**សព្វញ្ញុតញ្ញាណ**។
- ការសណ្ដូក**ព្រះហស្ត** និង**ព្រះបាទ**ចុះក្នុងសមុទ្រនោះ ជា**បុព្វនិមិត្ត**នៃកិរិយាសម្ដែងនូវ**ធម្មចក្រ**ដល់ទេវតា និងមនុស្ស
- **ការផ្ទំផ្ងារលើផែនដី** ជា**បុព្វនិមិត្ត**នៃកិរិយាធ្វើសត្វដែលមានមុខផ្កាប់ចុះឱ្យផ្ងារឡើង (គឺឱ្យឃើញច្បាស់នូវ**សច្ចធម៌**)។
- **កិរិយាផ្ទំបើកព្រះនេត្រ** ជា**បុព្វនិមិត្ត**នៃកិរិយាបាននូវ**ទិព្វចក្ខុ**។

- ការឃើញនូវពន្លឺភ្លឺដរាបដល់ភវគ្គព្រហ្ម ជាបុព្វនិមិត្តនៃអនាវរណញ្ញាណ។

## មហាសុបិនទី ២



ទ្រង់ឃើញស្មៅចិញ្ចៀន ដុះលេចពីនាភីឡើងនៅទល់នឹងអាកាស។

❖ ទ្រង់ព្យាករណ៍ថា៖

ការឃើញតិណជាតិដុះអំពីនាភី ជាបុព្វនិមិត្តនៃការសម្តែងនូវអដ្ឋង្គិកមគ្គ។

# មហាសុបិនទី ៣

## ព្រះអង្គឃើញដង្កូវទាំងឡាយខ្លួនស ក្បាលខ្មៅវារឡើង ពីចុងព្រះបាទា ដរាបដល់ព្រះជាណុមណ្ឌល។



❖ ទ្រង់ព្យាករណ៍ថា៖

ការឃើញនូវដង្កូវប្រែកាយ ជាបុព្វនិមិត្តនៃបរិស័ទទាំង ៤ ដល់នូវត្រៃសរណគមន៍ស្មើដោយជីវិត។

<u>បញ្ជាក់</u> : ក្នុងគំនូរនេះ មិនគូរសត្វដង្កូវទេ ប៉ុន្តែគូរបែបជាន័យត្រង់តែម្តង គឺគូររូបមនុស្សជំនួសវិញ។

# មហាសុបិនទី ៤



***ព្រះអង្គ**ឃើញ**សត្វបក្សី** ៤ ពួក មាន**វណ្ណៈ**ផ្សេងៗ ហើរពីទិសទាំង ៤ មកក្រាបទៀប**ព្រះបាទ** ហើយត្រលប់ជាមាន**វណ្ណៈ**សទាំងអស់។*

- ***ទ្រង់ព្យាករណ៍ថា៖***

  *ការឃើញ**សត្វបក្សី** ៤ ជាបុព្វនិមិត្តនៃត្រកូលទាំង ៤ ចេញ**សាងបព្វជ្ជា** ប្រព្រឹត្តតាម**ធម៌វិន័យ** (តែមួយដូចគ្នា)។*

## មហាសុបិនទី ៨

***ព្រះអង្គ**ទ្រង់ឃើញថា ទ្រង់យាង**ចង្រ្កម**លើភ្នំលាមកដ៏ធំ*

***ព្រះបាទា**មិនបានប្រឡាក់ដោយលាមកឡើយ។*

❖ ***ទ្រង់ព្យាករណ៍ថា៖***



*ការឃើញទ្រង់យាង**ចង្រ្កមលើភ្នំលាមក** គឺជា**បុព្វនិមិត្ត**នៃ**ចតុប្បច្ច័យ** ដែលកើតឡើងដល់**ព្រះអង្គ** តែ**ព្រះរាជហឫទ័យ**របស់**ព្រះអង្គ**មិនជាប់ជំពាក់ក្នុង**បច្ច័យ**ទាំង ៤ នោះឡើយ។*

*(ស្រង់ចាកសៀវភៅ ពុទ្ធប្បវត្តិកថា របស់**បណ្ឌិត ឈឹម សុមន៍**)*

*ចំណែកគំនូរក្រៅពីនេះ ជាគំនូរដែលពុទ្ធបរិស័ទធ្លាប់ឃើញច្រើនកន្លែងមកហើយ ខ្ញុំសូមមិនបរិយាយទៀតទេ ដើម្បីកុំឱ្យសៀវភៅនេះ មានទំព័រច្រើនពេក។*

# អ្នកមានឧបការៈក្នុងការជួយរៀបចំសៀវភៅនេះ

- យុវជនក្នុងសមាគមធម្មទានខ្មែរ-កូរ៉េ
- យុវជនក្នុងក្រុមយុវជន និងព្រះធម៌

} ជួយពិនិត្យអក្ខរាវិរុទ្ធ

- ឧបាសិកា រៀម សុខចំរើន
- ឧបាសិកា សុខ ចេង

} ជួយវាយអក្សរ និងសម្រួលអក្ខរាវិរុទ្ធ

- ឧបាសក តេ វិចិត្រ
- ឧបាសិកា ឡៅ ដានេ

} ជួយរចនាក្របសៀវភៅ

- ឧបាសក គឹម សុខតូ ជួយរត់ការផ្នែកបោះពុម្ព

# សៀវភៅធម៌ដែលបានរៀបរៀង
# ដោយ ភិក្ខុ ចជិរប្បញ្ញោ សាន សុជា

១. តើនរកមានដែរទេ? ព.ស. ២៥៤៦

២. ជីវិតពិតជាត្រូវការធម៌ ព.ស. ២៥៤៦

៣. ធម្មសង្គណី តិកមាតិកាសង្ខេប ព.ស. ២៥៤៨

៤. អភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៤ ព.ស. ២៥៤៨

៥. បងប្អូនជួបគ្នាមួយគ្រាមានន័យ ព.ស. ២៥៤៨

៦. ជីវិត ( Life ) ព.ស. ២៥៤៩

៧. ប្រយោជន៍ ៣ ប្រការ ព.ស. ២៥៤៩

៨. ព្រះធម្មបទ ៣០ គាថា ព.ស. ២៥៤៩

៩. រលកលោកធម៌ ព.ស. ២៥៥០

១០. អក្ខរវិធី និងធម៌នមស្ការ ព.ស. ២៥៥០

១១. ព្រះធម្មបទ ៣១ គាថា ព.ស. ២៥៥០

១២. ដំណើរជីវិត ព.ស. ២៥៥១

១៣. ព្រះធម្មបទ ៣២ គាថា ព.ស. ២៥៥១

១៤. សិង្គាលកសូត្រ ព.ស. ២៥៥២

១៥. ព្រះធម្មបទ ៣៣ គាថា ព.ស. ២៥៥២

១៦. ឧត្តមមង្គល ( The Great Blessings ) ព.ស. ២៥៤៣

១៧. ព្រះធម្មបទ ៣៤ គាថា ព.ស. ២៥៥៤

១៨. ព្រះធម្មបទ ៣៥ គាថា ព.ស. ២៥៥៤

១៩. ព្រះធម្មបទ ៣៦ គាថា ព.ស. ២៥៥៦

២០. មេរៀនចេតសិក និងចិត្ត អមដោយវីដេអូ ព.ស. ២៥៦៤

២១. មេរៀនរូបបរមត្ថអមដោយវីដេអូ (មិនទាន់បោះពុម្ព)

២២. មេរៀនបកិណ្ណកសង្គហៈ បរិច្ឆេទទី ៣ (មិនទាន់បោះពុម្ព)

**សៀវភៅធម៌ដែលបានរៀបរៀង**

**ដោយ ឧបាសក សាន សុជា**

២៣. មេរៀនវីថិសង្គហវិភាគ បរិច្ឆេទទី ៤ (កំពុងសរសេរនិងបង្រៀន)

២៤. ព្រះបទុមចេតិយ ព.ស. ២៥៦៧

សព្វទានំ ធម្មទានំ ជិនាតិ

*ធម្មទាន ឈ្នះអស់ទានទាំងពួង។*

*បោះពុម្ពលើកទី ១ ចំនួន ២០ ០០០ ក្បាល*

រោងពុម្ព អិមភី

MP Publishing House

រោងពុម្ព អិមភី phonmao@yahoo.com

Telegram www.mppublishinghouse.com

Tel.: 012 990 524 | 081 777 800 | 088 8888 908



# ព្រះបទុមចេតិយ

## វត្តមណីរតនារាម ភូមិថ្នល់បំបែក សង្កាត់រលាប

## ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

ចាប់ផ្ដើម ព.ស. ២៥៥២

ដល់ ព.ស. ២៥៦៧